# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

LIBRARY
BUDDHIST INST

ឆ្នាំទី ២៣ ខែកក្កដា លេខ ៧

ព.ស. ២៤៩៤ – គ.ស. ១៩៥១

## ជូនដំណឹង

# ដល់អស់លោកអ្នកជាវ "ព្រះត្រៃបិដក"

ពុទ្ធសាសនបណ្ឌិត្យ សូមជូនដំណឹងដល់អស់លោក - អ្នកជាវព្រះត្រៃបិដក ដ្បិតសៀវភៅខ្សែ ៣៦ ទើបនឹងចេញពីរោងពុម្ព, ដូច្នេះ អស់លោក-អ្នកនៅក្នុងក្រុងដែលបានចុះឈ្មោះជាវ សូមអញ្ជើញចូលទៅមន្ទីរនោះ ដើម្បីទទួលយកសៀវភៅតាមឈ្មោះ ដោយយកបង្កាន់ដៃជាប់ទៅជាមួយផង ។

ចំណែកអស់លោក - អ្នកនៅខេត្តក្រៅដែលបានចុះឈ្មោះជាវ គង់នឹងបានទទួលសៀវភៅនោះ ក្នុងពេលឆាប់ៗនេះ តាមរយៈផ្លូវសាលាខេត្ត ។

ឯអស់លោក-អ្នកដទៃទៀត ដែលមានបំណងចង់បានសៀវ-ភៅនោះ ក៏សូមអញ្ជើញទៅចុះឈ្មោះជាវយកនៅមន្ទីរពុទ្ធសាសន-បណ្ឌិត្យចុះ ។

សៀវភៅពីខ្សែ ៣៧ ទៅ កំពុងបោះពុម្ពតទៅទៀត ព្រមទាំងរើបោះពុម្ពពីខ្សែ ១-២ ឡើងវិញផង ។

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

---

បញ្ជីរឿង


| *ផ្នែកសាសនា* | | ទំព័រ |
|---|---|---|
| ពុទ្ធសាសនានិងគ្រិស្តសាសនា (សន្និសីទលោកវេជ្ជបណ្ឌិតម៉ិត្តូត់) (តមក) . . . | លោក ភ៉យ - ប៊ុក . . . . . . . . | ៤៨៣ |
| ពន្លឺអាស៊ី (តមក) . . . . . . . . . | លោក ភ៉យ - ប៊ុក . . . . . . | ៤៨៩ |
| អបាយមុខ . . . . . . . . . . . . . | ព្រះគ្រូសិរីសោភ័ណ កិម-ទួរ . . | ៤៩៣ |
| *ផ្នែកអក្សរសាស្ត្រ* | | |
| ការបណ្តុះនិស្ស័យ (តមក) . . . . . . . | ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៉ម . . | ៥០៧ |
| អ៊ីឡេណា - ស៊ីម្យ៉ាណា (តមក) . . . . | លោកផេង - ដ្រីវ . . . . . . . | ៥១៥ |
| រឿងសាមកុក (តមក) . . . . . . . . . . | ឧកញ៉ា នូ - កន . . . . . . . . . | ៥២៣ |
| ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក) . . | ឧកញ៉ា ឈឹម - ក្រសេម . . . . . | ៥៣៥ |
| រឿងអារក្សថ្លែងរឿងម្តេញប៉ា . . . . . . . . | លោក សង - សាភ័ត . . . . . . . | ៥៤២ |
| *កំណត់ទិនប្រវត្តិការណ៍* | | |
| ដំណើរមកកាន់ប្រទេសកម្ពុជានៃមហាបណ្ឌិត គុណបាលបិយសេន ម៉ាឡាល័សេកេរ . . | ពុទ្ធសាសនបណ្ឌិត្យ . . . . . . . . | ៥៥១ |


---


មួយឆ្នាំមាន ១២ សៀវភៅ ដំឡៃជារ ១៤៥៛,០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.


## TABLE DES MATIÈRES


### PARTIE RELIGIEUSE

| | | Pages |
|---|---|---|
| Bouddhisme et Christianisme (Conférence du Docteur A. Migot) (suite) | M. RAY-BUC . . . . . . . . . | 483 |
| La Lumière de l'Asie (suite) . . . . | M. RAY-BUC . . . . . . . . . | 489 |
| Apayamukha . . . . . . . . . | PRAH-KROU-KEM-TO . . . . . . | 497 |

### PARTIE LITTERAIRE

| | | |
|---|---|---|
| Education morale (suite) ......... | Prah Maha PEUNG-PAM . . | 507 |
| Histoire d'Hélèna-Simiana (suit ) . | M. PHENG-CHRIEU . . . . . . | 515 |
| Histoire de SAMKOK (suite) . . . . | Oknha NOU-KAN . . . . . . | 523 |
| Histoire du Royaume du Cambodge (suite . . . . . . . . . . . . . . . . | Oknha CHHIM-KRASEM . . . | 535 |
| Les vingt-cinq récits du mauvais génie «Conte indien» . . . . . | M. SANG-SAVAT . . . . . . . | 542 |

### NOTES ET CHRONIQUES

| | | |
|---|---|---|
| Voyage au Cambodge du Dr. G. P. Malalasekera, Président du Centre Mondial des Bouddhistes de Ceylan | Institut Bouddhique. . . . . . . | 550 |



Prix d'abonnement annuel comprenant 12 numéros: 145$00

# ពុទ្ធសាសនា និង គ្រិស្តសាសនា

## សន្និសិទលោកវេជ្ជបណ្ឌិតមីគូត៍

លោក ព៉យ-ប៊ុក គ្រមការ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីទស្សនាវដ្ដី "ហ្វ្រង់អាស៊ី" ខែមិថុនា ឆ្នាំ ១៩៥០

(តមក)

---

ព្រះពុទ្ធសាសនានៅស៊ីឡង់ ឬ កម្ពុជរដ្ឋមិនដូចព្រះពុទ្ធសាសនានៅប្រទេសជប៉ុន ឬ ទីបេត៍ទេ; ព្រះពុទ្ធសាសនានេះមានន័យខុសទៅតាមជាតិ តាមអាកាសធាតុ តាមស្ថានទីដែលពួកពុទ្ធសាសនិកជននោះបានស្ថិតនៅ តាមមជ្ឈដ្ឋាននិងតាមកិច្ចត្រូវការខាងមិនបានខាងផ្លូវប្រាជ្ញា ។ ហេតុដែលធ្វើឲ្យព្រះពុទ្ធសាសនាមានតម្លៃ គឺការចលនានៃព្រះពុទ្ធ-សាសនា, ការពិសោធន៍ខាងវិធីប្រតិបត្តិ ចំពោះពុទ្ធសាសនិកជនម្នាក់ៗ, ការព្យាយាមនៃពុទ្ធសាសនិកជន ទៅតាមមូលដ្ឋាននិងគោលការណ៍ជាសាធារណ៍តែមួយដូចគ្នា អហេតុកធាតុសញ្ញាណចំពោះសាសនិកជនយ៉ាងណាក៏ដោយ សមតិនាមយ៉ាងណា ការសំខាន់បំផុតគឺការសម្រេចឲ្យដល់អហេតុកធាតុចំពោះខ្លួន ៗ ឯង ៗ ការដែលអប់រំព្រះពុទ្ធសាសនាទៅតាមគតិជាតិទាំងអស់ក្នុងពិភពលោក ជាហេតុធ្វើឲ្យព្រះពុទ្ធសាសនា

មានឥទ្ធិពលសម្បើមអស្ចារ្យ ។ ព្រហ្មញ្ញសាសនានិងសាសនាអ៊ីស្លាម ច្រើនជាសាសនាពិសេស ; គ្រិស្តសាសនាបានរក្សាទុកនូវលោកវិជ្ជា បរមត្ថវិជ្ជា ឲ្យាក់គោលខាងសាសនាស៊ុយដាអ៊ីក (judaïque) និងក្រិក (hellènique) ដែលពួកខាងបូព៌ាប្រទេសមិនអាចយល់បានឡើយ ។ ព្រះពុទ្ធសាសនាមានសភាពស្រួលអាចយកទៅនិយមប្រើនៅប្រទេសក្រៅៗ ពីប្រទេសឥណ្ឌានិងជប៉ុនបាន ; ព្រះពុទ្ធសាសនាអាចតម្រូវចិត្តទាំងជាតិទីបេតដែលនិយមប្រើមន្តអាគម និងជាតិអឺរ៉ុប ដែលនិយមប្រើទៅតាមវិចារណញ្ញាណលទ្ធិ ។ ដោយហេតុនេះហើយបានជាព្រះពុទ្ធ-សាសនា ជាសាសនាអាចប្រតិស្ឋានកាន់តែច្រើនឡើងនៅបច្ចិមប្រទេសបាន ។ ហេតុខាងលើនេះ បង្ហាញឲ្យយើងឃើញជាក់ស្តែងនូវជីវ័ននិងស្ថិរភាពនៃព្រះពុទ្ធសាសនា ក្នុងសម័យបច្ចុប្បន្ន ។ ចំណែកខាងពួកបេសកជនខាងគ្រិស្តសាសនា ពិតមែនតែប្រកបដោយព្យាយាមយ៉ាងម៉ឺងម៉ាត់ ព្រមទាំងមានថាមភាពយ៉ាងរឹងប៉ឹង ក៏មិនអាចនឹងញ៉ាំងពួកប្រជាជនដែលកាន់ពុទ្ធសាសនា ឲ្យជឿជាក់ប្រព្រឹត្តប្រតិបត្តិតាមខ្លួនបានឡើយ ។

មានផ្នែកផ្សេងពីនេះទៀតដែលជាការកាន់ច្រឡំ ដូចយើងបានពោលខាងលើនេះ នាំឲ្យអ្នកទាំងពួងប្រមាថមើលងាយខ្លាំង គឺផ្នែកខាងសីលធម៌ ។ បើតាមអ្នកឯកទេសខាងបច្ចិមប្រទេសខ្លះ យល់ថា

សីលធម៌ខាងព្រះពុទ្ធសាសនាមានសភាពខាងប្រាជ្ញាសុទ្ធ ប្រកបដោយអកម្ម, អចលនភាព ហើយឧត្តមគតិខាងព្រះពុទ្ធសាសនា គឺឧត្តមគតិក្នុងការរួចចាកទុក្ខទាំងពួងប្រកបដោយអត្តទត្តភាព (ចំពោះខ្លួនឯង)។ គេអាចស្រាវជ្រាវរកបានតាមគម្ពីរភាសាបាលី, មានអត្ថបទជាច្រើនបញ្ជាក់ឲ្យឃើញច្បាស់លាស់នូវយោបល់ខាងលើនេះ តែអត្ថបទទាំងនុ៎ះជាសភាវៈពិសេស ហើយជាអនិច្ចតាភាពនៃព្រះពុទ្ធសាសនា ។ បើតាមពិនិត្យនូវទម្រង់នៃអត្ថបទទាំងនោះ ឃើញថាជាអត្ថបទប្រកបដោយសីលធម៌ តែមានរូបភាពអាចយកទៅនិយមប្រើជាផ្លូវការនូវសាលារៀន តែមិនសូវមានឧជារស ។ តាមសភាពផ្ទុយ, បើពិនិត្យឲ្យដឹងឆ្ងាយនៃវិជ្ជាខាងព្រះពុទ្ធសាសនា, បើគេចូលមកសេពគប់នឹងប្រជារាស្ត្រដែលកាន់ព្រះពុទ្ធសាសនាម៉ឹងម៉ាត់ គេអាចឃើញដោយឆាប់រហ័សថា ន័យព្រះពុទ្ធសាសនាខាងបច្ចិមប្រទេស មានសភាពខុសគ្នាពីធម្មតាលោក ហើយមិនត្រូវទៅតាមសច្ចធម៌ទេ ។

ឯកសារពីសម័យបុរាណ ដែលបានតកល់ទុកចំពោះរឿងព្រះពុទ្ធសាសនា មានសិលាចារឹកនៃព្រះបាទអសោក អធិរាជនៃប្រទេសឥណ្ឌាសម័យបុរាណ ដែលសោយរាជសម្បត្តិពី ២៧៤ ទៅ ២៣៦ មុនគ្រិស្តសករាជ ។ ព្រះមហាក្សត្រិយ៍អង្គនេះទ្រង់ជាពុទ្ធសាសនូបត្ថម្ភក៍, ទ្រង់បានចាត់ឲ្យយករឿងពុទ្ធសាសនាមកចារឹកទុក នៅផែនសិលានៅភូមិភាគ

ក្នុងព្រះរាជអាណាចក្រ ហើយសិលាចារឹកនោះបានឲ្យពត៌មានអំពីរបៀបព្រះពុទ្ធសាសនាក្នុងរវាងសតវត្សក្រោយសង្គាយនា នៃធម៌នឹងវិន័យជាភាសាបាលី ។ មានសិលាចារឹកមួយថ្លែងថា ច្បាប់នៃសាសនាមានសភាពវិសេស ; ច្បាប់នោះខ្ទានថា មិនត្រូវប្រព្រឹត្តបាបត្រូវបំពេញបុណ្យឲ្យច្រើន, ត្រូវធ្វើទាន, កាន់សុចរិត, ធ្វើជីវភាពឲ្យបរិសុទ្ធស្អាត ។ យើងខ្ញុំបានធ្វើទានជាអនេកប្បការ ដល់សត្វលោកទាំងអស់មានមនុស្សនឹងសត្វតិរច្ឆានជាច្រើនបែបច្រើនយ៉ាង ។ យើងខ្ញុំបានផ្សាយសេចក្តីអនុគ្រោះដ៏ពន្លឹក រហូតដល់ជួយឧបត្ថម្ភឲ្យសត្វទាំងអស់មានទឹកបរិភោគគ្រប់ៗគ្នា ; អ្នកណាបានធ្វើយ៉ាងនេះ ហៅថាបានបំពេញកុសល ។ គេច្រើនមើលឃើញតែត្រង់បុណ្យដែលខ្លួនបានធ្វើ, គេមិនអាចឃើញនូវបាបដែលខ្លួនប្រព្រឹត្តទេ ឬ គេមិនចង់ពោលពីបាបដែលគេធ្វើ, យើងខ្ញុំបានប្រព្រឹត្តនូវកម្មកភាពដ៏លាមកខ្លះដែរ ។ ការដែលយើងខ្ញុំទទួលខ្លួនខុសត្រង់ការប្រតិបត្តិជាការលំបាក, តែត្រូវត្រួតត្រាខ្លួនដោយខ្លួនឯង ; ហើយពោលចំពោះខ្លួនថា : មានអំពើខ្លះជាបាប ដូចទោមនស្សចិត្ត, សេចក្តីក្រោធ, ទារុណភាពឬភាពកាច, មានះ (Orgueil) ត្រូវពោលចំពោះខ្លួនថា · ខ្ញុំមិនព្រមប្រព្រឹត្តលោភ (envie) នោះទេ ; ខ្ញុំមិនពោលពាក្យបំផ្លើស, បង្កាច់ (ធរុសវាទ) ទេ ; ដោយការប្រព្រឹត្តបែបនេះ ខ្ញុំអាចរក្សាសេចក្តីសុខក្នុងលោកនេះនឹងបរលោកបាន ។ តើជា

សីលធម៌មានសភាពជាអកម្មប្រកបដោយអចលនភាពឬ? ត្រូវអ្នកយល់ថាអត្ថបទនោះមានពណ៌នាអំពីទានប្រកបដោយសកម្ម, ចិត្តល្អហើយនិងចិត្តសន្ដោស តាំងពីបីសតវត្ស មុនព្រះគ្រិស្តបដិសន្ធិ គឺមិនមែនលោកសង្ស័យកំសត់ទេដែលមានពុទ្ធដីកានេះ គឺព្រះអធិរាជដ៏មានពលភាពអស្ចារ្យមានព្រះរាជឱង្ការនូវព្រះបន្ទូលសូរសីហនាទ ចំពោះអ្នកនៅក្រោមអំណាចព្រះអង្គ ៗ នេះជាធម៌ដែលព្រះពុទ្ធសាសនា បានទូន្មានប្រទេសឥណ្ឌាតាំងពីពីរសតវត្សមកហើយ ៗ

បើយើងបានអានគម្ពីរបាលី យើងនឹងឃើញនូវព្រះបរមពុទ្ធោវាទប្រកបដោយសីលធម៌ដូចគ្នានឹងសិក្ខាបទ ស៊ុយដាអ៊ីក (Décalogue judaïque) កុំសម្លាប់, កុំលួច, កុំពោលពាក្យកុហក, កុំប្រព្រឹត្តកន្លងកិរិយាអ្នកដទៃនឹងស្ត្រីដែលគេហួងហែងរក្សា (អព្រហ្មចរិយធម៌) ៗ ល ៗ តែក្រៅពីព្រះបរមពុទ្ធោវាទប្រកបដោយអវិជ្ជមាន (négatif) នេះ មាននៅពាសពេញក្នុងគម្ពីរនោះ ព្រះពុទ្ធោវាទដទៃទៀតប្រកបដោយសីលធម៌ដូចគ្នានឹងឱវាទនៃព្រះគ្រិស្ត ៗ តើវាចាវិសេសដែលព្រះសម្មាសម្ពុទ្ធទ្រង់ទេសនាមាននៅក្នុងគម្ពីរធម្មបទមិនស្មើនឹងឱវាទព្រះគ្រិស្តឬ? ដូចជា "សេចក្ដីស្អប់មិនអាចរម្ងាប់បានដោយសេចក្ដីស្អប់, សេចក្ដីស្អប់អាចរម្ងាប់បានដោយសេចក្ដីស្រឡាញ់" ឬថា "ត្រូវប្រើចិត្តសន្ដោសចំពោះអ្នកគ្មានសន្ដោស, ប្រើចិត្តល្អចំពោះអ្នកកាច, ប្រើចិត្តទូលំទូលាយចំពោះ

មនុស្សលោក, ឲ្យបំបាត់សេចក្ដីក្រោធខឹងដោយចិត្តមេត្តាល្អ, សេចក្ដីអាក្រក់ដោយសេចក្ដីល្អ, ពាក្យកុហកដោយពាក្យសច្ចៈ" ។ ពាក្យដូចពណ៌នាខាងក្រោមដែលប្រែហលដកស្រង់ពីសៀវភៅ ហ្វីអូរេទី (fioretti) នៃលោកហ្វ្រង់ស្វាដាស៊ីស (François d'Assise) បើមានមនុស្សគាបធ្វើទុក្ខលំបាកដល់អ្នក ត្រូវកុំបណ្ដោយឲ្យចិត្តខឹងមកគ្របសង្កត់បាន, កុំធ្វើចិត្តឲ្យឃ្វេងឃ្វាង, កុំឲ្យពាក្យអសប្បុរសចេញពីបបូរមាត់ឲ្យសោះ, ចូរអ្នកតំកល់ចិត្តឲ្យល្អ, ចិត្តប្រកបដោយព្រហ្មវិហារផុតចាកសេចក្ដីកំណាច ។ ចូរអ្នកផ្សាយចិន្ដាប្រកបដោយមេត្តា, ប្រាសចាកសេចក្ដីខឹង, ស្អប់" ។ នេះហើយជាសីលធម៌នៃព្រះពុទ្ធសាសនា ដែលគេបានចារិកមកក្នុងគម្ពីរបាលី ជាសីលធម៌យ៉ាងជាន់អន់មិនសូវមានឧជារស ហើយប្រែនគេយកទៅនិយមអនុវត្តន៍តាមសាលារៀន ។

(មាឧត)

# ពន្លឺអាស៊ីទ្វីប

## វគ្គទី ៦

La Lumière de l'Asie

លោក ស៊ីរ-អេតវិន អារណូលត៍ តែង

## លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

គ្មានបុគ្គលណា អាចលះបង់នូវកាមច្ឆន្ទៈ ប្រកបដោយសេចក្ដីព្រួយលំបាក ឬទុក្ខដែលទៅតួនសម្ងំខាងក្នុងបញ្ចេញមកក្រៅ ជាសភាពគួររីករាយទេ បើបុគ្គលនោះមិនទាន់បានវិជ្ជាដែលពន្យល់ឲ្យដឹងនូវឧបសគ្គផ្សេងៗ ដែលរាំងរាមិនឲ្យឃើញធម៌; តែបើអ្នកណាស្គាល់ច្បាស់នូវវិជ្ជាសភាពក័ទ្ដប្រចាំ អ្នកនោះអាចចៀសវាងនូវឧបសគ្គនោះបាន, លែងពេញចិត្តខាងការស្នេហានូវជីវភាព តែខំព្យាយាមចាកចេញពីជីវភាពនេះបានៗ បញ្ញាចក្ខុអ្នកនោះបានយល់ច្បាស់ឃើញជាក់ក្នុងចិត្តថា អវិជ្ជាជាបច្ច័យនាំឲ្យកើតសង្ខារ (ពាលទុច្ចរិត) ហើយនឹងវិញ្ញាណ (ថាមភាព, énergie) ដែលនាំឲ្យកើតនាមរូប (ទម្រង់បុគ្គលិកលក្ខណៈ, forme individuelle) បុគ្គលិកលក្ខណៈ (personnalité) សំបករូប (enveloppe corporelle) ដែលធ្វើឲ្យបុគ្គលបណ្ដោយវេទនាឲ្យធ្វើតាមទំនើងចិត្ត ឥតអ្វីមកការពារបាន, កញ្ចក់ដែលឆ្លុះឲ្យឃើញក្នុងហទយវត្ថុនូវអារម្មណ៍ដែលមិនពិត, នេះហើយ ហេតុដែលឲ្យចំរើនមានវិយវដ្ឍនាការឡើងនូវវេទនា (ជីវភាព

នៃអារម្មណ៍) (la vie de sens) ព្រមទាំងសេចក្ដីសប្បាយដែលខុសចាកគន្លងធម៌នឹងទុក្ខលំបាក, តែវេទនានោះ បើទុកជាទោមនស្សឬសោម-នស្ស ជាហេតុឲ្យកើតតណ្ហា (désir) គឺការស្រេកឃ្លានដែលនាំឲ្យអ្នករស់នៅក្នុងភពអណ្ដែតត្រសែតលើគង្គា ក្រេបផឹកនូវលោកដែលមានរសជាតិប្រៃ ហើយមានសភាពបេះប្រែកិច្ចកលផ្សេងៗ គឺសាមិសសុខ (plaisir), មហិច្ឆតា (ambitions), ភោគទ្រព្យ (richesse). កិត្តិគុណ (Gloire), កិត្តិស័ព្ទ (renommée), អំណាច (domination), លទ្ធកម្មដោយអាវុធ (Conquêté), សេចក្ដីស្នេហានឹងភោជនាហារ ដែលមានរសជាតិ, គ្រឿងសំលៀកបំពាក់ល្អឆើត, ព្រះបរមរាជវាំងសម្បើមអស្ចារ្យ, មានៈ (orgueil) ពីកំណើត, កាមច្ឆន្ទៈ (concupicence), ការសង្គ្រាមដើម្បីជីវិត ហើយនឹងផលដែលបានពីការសង្គ្រាមនោះ ខ្លះផ្អែមខ្លះល្វីង ៗ ព្រោះហេតុដូចនេះ សេចក្ដីស្រេកនៃជីវភាព នាំឲ្យក្រេបផឹកនូវទឹកស្រវឹងដែលនាំសត្វឲ្យកាន់តែស្រេកឡើងថែមទៀត; តែបណ្ឌិតបានដកលើងនូវឫសនៃតណ្ហាចេញចាកសន្ដាន ហើយលែងបំប៉នអាហារ គឺអារម្មណ៍ដែលបញ្ចេញនូវស្រមោលផ្សេងៗ នាំឲ្យចិត្តកន្ទ្រែចឡើងនោះ ៗ បណ្ឌិតទម្លាប់ចិត្តរបស់លោកឲ្យនៅនឹង ឥតកម្រើក, លែងស្វែងរក, លែងតស៊ូ, លែងបំផ្លាញអ្នកដទៃ, លោកទទួលដោយហសនចិត្តនូវបាបអកុសលដែលលោកបានប្រព្រឹត្តពីអតីតជាតិមក, លោកអាចសម្លាប់នូវ

តណ្ហានេះបាន, ព្រោះហេតុដូចនេះ ការប្រមូលនូវជីវភាពទាំងអស់, កម៌ (karma), ការប្រមូលអាត្ម័នដែលមានកម្មកភាពនឹងបិន្តាអតីត: ជាសមាសភាព, អាត្ម័នដែលលោកបានយកកាលព្រមទាំងកិច្ចការមើលមិនឃើញមកត្រងវេញជាមួយហើយត្បាញឲ្យជិតស្និទ្ធយូរមកហើយ ត្រឡប់ទៅជាមានលទ្ធផលចំពោះលោកធាតុ ប្រែសភាពជាបរិសុទ្ធហើយផុតបាកអកុសលកម្មទាំងអស់ ។ ម្ល៉ោះហើយ, បណ្ឌិតមិនត្រូវការនឹងស្វែងរករូបបដិសន្ធិជាថ្មីទៀត នឹងភព ឬជាត្រូវបន្ទាបម្រង់ជាថ្មីកង់ជីវភាពនោះ ហើយក៏ប្រព្រឹត្តនូវធម៌ដែលនាំឲ្យទុក្ខនោះ កាន់តែស្ដើងស្ដួចចុះទៅតាមលំដាប់ លុះត្រាតែបានផុតរលត់ដល់អវសាន, ហើយលោកក៏បានធ្វើដំណើរទៅដល់ចុងផ្លូវ (មគ្គសច្ច). លោកក៏ផុតស្រឡះពីសេចក្ដីកន្តច្រឡំដែលមានពាសពេញលើផែនដី ព្រមទាំងស្កន្ធ[1] (ខន្ធ) ទាំងអស់នឹងរាគាទិកិលេស, លោកបានកាច់បំបាក់នូវចំណងមារគឺឧបាទាន, លោកលែងវិលទៅតាមលំនាំនៃកង់លោក, លោកភ្ញាក់ពីនិទ្រាហើយគ្រាកដឹងខ្លួនសប្បាយរីករាយក្នុងចិត្ត ដូចមនុស្សដែលគេឲ្យឱសថក្រេបផឹកបាត់លែងរវើរវាយ ៗ រួចមានសភាពឧត្ដមជាងមហាក្សត្រិយ៍ សុខស្រួល

១ ស្កន្ធ ឬ ខន្ធ គឺ កងវត្ថុធាតុដែលប្រមូលទៅកើតជាបុគ្គល (individu) មាន៥ប្រការ ទី ១ គុណភាពខាងសម្ភារៈ (វិសាលភាព, សភាពរឹង ពណ៌); ទី ២ វេទនារម្មណ៍; ទី ៣ វិចារ (perceftion) ការសំគាល់ (jugements); ទី ៤ អាកប្បកិរិយានៃសីលធម៌និងចិត្ត; ទី៥ ចិត្ត ឬ ញាណ ។ គ្មានវត្ថុធាតុណាមួយជាធាតុស្ថិតថេរបោរកាលឡើយ គឺជាវត្ថុមិនទៀងទាំងអស់ ។

ជាន់ព្រះព្រហ្មព្រះឥន្ទនឹងទេវតា, លោកក៏បានទៅដល់អវសានជាតិផុតពីសេចក្ដីទុក្ខនៃជីវភាព ហើយទៅជួបនឹងជីវភាពបែបថ្មីដែលមិនមែនជាជីវិតក្នុងលោក, ក្នុងលើកដំបូង ពេលនោះគឺសេចក្ដីស្ងប់ជាអស្ចារ្យ សេចក្ដីសុខជានិរាមិសសុខគឺនិព្វាណ (ព្រះនិព្វាន) ជាទីគោរព ជាទីឈប់សម្រាកគ្មានបាបអកុសល គ្មានកង្វល់រវល់ ជាញាណប្រែប្រួល តែមិនអាចប្រែភាពទៅជាអ្វីឡើយ ។

ក្នុងមួយរំពេចនោះ បុព្វណ្ហសម័យក៏បញ្ចេញរស្មីត្រចះត្រចង់ បញ្ជាក់ឲ្យឃើញនូវជោគជ័យព្រះសម្មាសម្ពុទ្ធ, រស្មីជាបឋមនៃព្រះអរុណចាំងចែងពីទិសបូព៌ា ចូលទៅជ្រែកទំលុះនៃផ្ទាំងខ្មៅងងឹតនៃនិសា (Nuit) ។ នៅលើមេឃ, ផ្កាយព្រឹកបានបញ្ចាំងអាភា មានពណ៌សដូចប្រាក់ រួចបាត់ពីទីនោះទៅ ហើយមានរស្មីពណ៌កុឡាបស្រស់ក្លីពាសពេញនភាល័យចោលមក ផ្លូតពីលើអដ្ឋាកាសមានពណ៌ប្រផេះ ។ នៅឆ្ងាយ, មានគិរីដែលមានស្រមោលរុំព័ទ្ធជុំវិញ ហើយមានពពកមានពណ៌ក្រហមឆ្អៅអណ្ដែតពីលើដូចជាគេពាក់មួដ មានគេទៅឃើញព្រះសុរិយាមុននឹងពិភពលោកភ្ញាក់ពីនិទ្រា ។ វាយោក្ដៅល្មមនៃសាយណ្ហសម័យផាយផាត់តាមបុប្ផា ហើយធ្វើឲ្យស្រទាប់បុប្ផាទាំងនោះបើករីកពាសពេញប្រថពី ។ អាកាសត្រាច់ដើរលឿនហើយប៉ះពាល់ដល់តិណជាតិដែលមានទឹកសន្សើមជឹតជាមជុំវិញ ហើយដល់ព្រះអរុណរះឡើងទឹកសន្សើម

នោះទៅជាគ្រឿងអលង្ការដ៏ប្រសើរអស្ចារ្យគួរឲ្យពេចពិលរមិលមើល, ធ្វើឲ្យប្រែពីទាំងមូលក្ដីចាំងថែងអស្ចារ្យ, របនារិមពពកដែលមានសភាពខ្មៅ បោកផាត់ដោយខ្យល់ព្យុះសង្ឃ្រាក ហើយបាត់ទៅឲ្យមានរំយោលជរផាយប្រកបដោយសុវណ្ណពណ៌, ចាំងស្លឹកកំពូលនៃតាលព្រឹក្សឲ្យមានពណ៌ក្រហមដូចមាស ហើយស្លឹកនោះទោរទន់ដោយព្រះពាយផាយផាត់ដូចជាគេធ្វើគារវភាព, ធ្វើឲ្យព្រៃពោះឲ្យមានពណ៌ក្រហមស្រស់ហើយធ្លាក់ទៅដល់ទឹកក្នុងស្ទឹង ដូចជាគេគោះបង្អើះទិព្វនៃទេពធីតាទៅលើទឹកនោះ ប្រែទៅជាមានពណ៌ក្រហមទទឹម ក្ដីពលដាលពាសពេញ ចុះទៅត្រង់គុម្ពោតវនប្បទេសទៅចំក្អែកស្ទូតនៃប្រែស ដែលដេកស្ងៀមនៅទីនោះ ៗ អាកានោះពោលថា: "ថ្ងៃរះហើយ" ប៉ះពាល់ដល់សំបុកដែលមានកូនបក្សាដេកលក់ប៉ុាំងក្រោមស្លាបហើយខ្សឹបថា: 'ឱអ្នកនាង, ចូរមើលពន្លឺព្រះអរុណ" ៗ រួចបក្សាទាំងអស់ក៏បញ្ចេញសូរស័ព្ទអឺងកងរំពង ៗ មានចំរៀងបក្សា កូអ៊ីអូល (Koil) ដូចគេផ្លុំខ្លុយ, ទំនុកនៃសត្វគុកថា "ព្រឹក, ព្រឹក", អាអូតមានស្លាបរលេចពណ៌ជាច្រើនបែបដូចគំនូរ, ស្ទូរសៀងបក្សាចចៃ្រួចហើរលើអាកាសទៅស្វែងរកទឹកឃ្មុំមុនទឹងកមក់ចេញពីសំបុកវា, សំឡេងកាកាខ្មៅងងឹត, សូរដូចកញ្ចែនៃសត្វសេក, សូរបក្សាត្រសេះខៀវស្រែងាត់ពោះរុក្ខា, សំឡេងសារិកា-កែវ, ស័ព្ទលលកទាំងបើកបទស្នេហាគូវា ៗ ផលដែលបានមកក្នុង

បុត្តណ្ហាសម័យដែលបញ្ចេញអានុភាពជាអស្ចារ្យ ជាមួយនឹងជោគជ័យនៃព្រះសម្មាសម្ពុទ្ធ បណ្តាលឲ្យតាមភូមិជិតឆ្ងាយក្នុងលោកសន្និវាសនេះ មានសន្តិសុខចូលទៅស្ថិតគ្រប់គេហដ្ឋានមនុស្សទាំងអស់ ៗ បើកាលណាគេឡើងទៅយល់សាយណ្ហាសម័យបញ្ចេញរស្មីស្រទន់ពាសពេញផែនដី, នាយពេជ្ឈឃាតលាក់កាំបិត, ពួកចោរបោះបង់ចោលនូវភោគទ្រព្យ, ពួកសារាហ្វ Sharaff)(១) ក៏រាប់ប្រាក់ឲ្យត្រឹមត្រូវ; អ្នកណាដែលមានចិត្តកាចពាលត្រឡប់ជាស្លូតល្អទៅវិញ, អ្នកណាដែលល្អប្រែជាវិសេសថ្លៃថ្លា ៗ មហាក្សត្រិយ៍ដែលធ្វើសង្គ្រាមបង្អង់ស័ន, ពួកអាពាធក្រោកឡើងសើចសប្បាយលើគ្រែជម្ងឺ, អ្នកដែលជិតមរណភាពញញឹម ដូចជាធ្លាប់បានដឹងថាបច្ចូសសម័យនេះបញ្ចេញពីប្រកត ដែលឆ្ងាយលន់លឹមលន់លោចពីដើងមេឃឯទិសបូព៌ា ៗ ហើយក្នុងពេលនោះ ព្រះទ័យព្រះនាងយសោធរាដែលរង់ទុក្ខលំបាកគង់នៅលើគ្រឡាព្រះបន្ទំព្រះអគ្គម្ចាស់សិទ្ធត្ថ ស្រាប់តែមានរស្មីជាសពាសពេញចេញកំសួលសុខស្រួលសប្បាយក្នុងមួយរំពេច ហើយព្រះនាងស្មានក្នុងព្រះទ័យថា សេចក្តីស្នេហារបស់ព្រះនាងចំពោះព្រះអង្គ មិនមែនធ្វើឲ្យព្រះនាងភ័ន្តគំនិត ហើយសេចក្តីទុក្ខរបស់ព្រះនាងនឹងអស់ត្រឹមពេលនេះ ប្រែទៅជាសុខដ៏ធំទូលាយទៅវិញ ៗ ចំណែកខាងពិភពលោកទៅជាសប្បាយ; ដោយ

---

១ សារាហ្វ; ធនាគារ, អ្នកដូរប្រាក់ ។

មើលហេតុនោះពុំឃើញ ហើយនៅពីលើកលខ្យាចរហោស្ថាន ដែលជាទីស្មសាន គេបានឮស័ព្ទសូរបំរៀងពួកប្រេត[1] នឹងពួកបុត្រៈ (ប្រហែលជាបិសាច) គ្មានកាយ ដែលបានដឹងនូវជោគជ័យនៃព្រះសម្មាសម្ពុទ្ធ; ហើយពួកទេវៈស្រែកឮកណ្តាលនភាល័យៈ "អស់ហើយ, អស់ហើយ" ។ ព្រះភិក្ខុសង្ឃគង់ឈរតាមវិថីជាមួយនឹងប្រជារាស្ត្រ ដោយងឿងឆ្ងល់, ក្រឡេកមើលទៅអាកាសមានពណ៌ដូចមាស ដែលផ្សព្វផ្សាយពេញមហាមេឃៈហើយពោលថាៈ "ប្រហែលមានព្រឹត្តិការណ៍អ្វីប្លែកអស្ចារ្យ!" ។ ហើយនៅកង់រង[2] នឹងអរញ្ញប្រទេស ពួកសត្វលោកសំដែងនូវមិត្តភាពទៅវិញទៅមក; រមាំងមានកាយពណ៌ពពាលបរិភោគស្មៅជាសុខនៅជិតខ្លាញីដែលកំពុងបំបៅកូន, សត្វខ្លាខិនអាស្រ័យទឹកជិតឈ្លូស, សត្វទន្សាយពណ៌ប្រផេះ រត់នៅក្រោមថ្មសិលាដែលបក្សាអកកំពុងយកចំពុះសៀតស្លាបរលេងកំសាន្ត ។ ពស់វែកហាលថ្ងៃ មានកាយពណ៌ខ្ចតវៀនហើយបញ្ចូលចង្កូមពិសទៅក្នុងមាត់វិញ ។ បក្សាខ្វែងបណ្តាយឲ្យសត្វចាបចៀបកប្បាស (Pinson) ធ្វើសំបុក, ត្រចៀកកាំសមុទ្រ (alcyons) ពណ៌នីលដេកយល់សប្តិចំឡែក, ចំណែកឯមច្ឆជាតិហែលសប្បាយឥតមានភ័យនៅជិត; បក្សាមេរុប (Mérops) (ប្រហែលជាប្រចៀវ) នៅស្ងៀមពិតមែនតែមេអំបៅមានពណ៌ក្រហមឆ្អៅ ខៀវ ផ្ទៃមេឃ ឬលឿង ប្រផេះ

---

១ ប្រេតៈ ព្រលឹងអាត្មានៃសត្វ ដែលៈធ្វើមរណភាពទៅហើយ ។ ២ រង់ (Ran) ភិលស្មៅ

ហិចហើរជាហ្វូងនៅជុំវិញទ្រនំក់, ដោយហេតុនេះហើយព្រះទ័យព្រះសម្មាសម្ពុទ្ធបានផ្សាយចំពោះមនុស្សលោក, បក្សាទាំងអស់, សត្វតិរច្ឆាន, តែចំណែកព្រះអង្គកំពុងពិចារណា នៅក្រោមម្លប់ពោធិព្រឹក្សដម្កល់នៅក្នុងការជោគជ័យ ការដែលព្រះអង្គឈ្នះកិលេសមារ ដើម្បីមនុស្សទាំងអស់ ហើយព្រះប្រាជ្ញាកំពុងមានរស្មីភ្លឺស្វាងរុងរឿងដូចថ្ងៃ ។

ក្នុងអវសាន, ព្រះអង្គមានហសិតុប្បាទចិត្តប្រកបដោយទសពល-ញាណ, ទ្រង់តើនឡើងចេញចាកអជ្ឈបាលនិគ្រោធហើយបន្លឺព្រះសូរសីហនាទជាប្រថមថា ដែលអ្នកទាំងអស់ក្នុងសាកលលោកធ្លាប់បានឮគ្រប់កាលថា :

« អញបានស្ថិតនៅក្នុងគេហដ្ឋានជាច្រើនជីវភាព, ស្វែងរកបុគ្គលណាដែលសង់ពន្ធនាគារដែលប្រកបដោយផស្សារម្មណ៍ ជាហេតុឲ្យកើតទុក្ខ ហើយអញបានតស៊ូជានិរន្តរកាល, លំបាកព្រួយពីមុនមក ។ តែឥឡូវនេះ, ឯងដែលជាអ្នកស្ថាបនិកនៃខន្ធនេះអញស្គាល់ច្បាស់ហើយ, តទៅអនាគត ឯងលែងស្ថាបនានូវកំពែងនេះដែលពេញទៅដោយទុក្ខ, ឯងលែងសង់មេដំបូលនៃចំបាយកលទុច្ចរិត ហើយឯងលែងដាក់ផ្តាំងថ្មលើដីឥដ្ឋនេះហើយ, គេហដ្ឋានឯងវិនាសហើយ, ឯផ្ទានគឺអវិជ្ជាជាស្ថាបនិកនៃគេហដ្ឋាននោះបាក់បែកអស់ហើយ ។ តាំងពីថ្ងៃនេះតទៅ, អញនឹងត្រេចប្រោសសត្វ ឲ្យរួចពីកណ្តាប់ដៃឯង !» ។

(មានត)

# ព្រះគ្រូសិរីសោភ័ណ កឹម - ត្វូរ ក្រុមជំនុំព្រះត្រៃបិដក

ទេសនាផាក់វិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា

**កាលពីថ្ងៃ ៨ កើតខែកត្តិក ឆ្នាំករនព្វស័ក ព. ស. ២៤៩០**

**(២០ - ១១ - ៤៧)**

---

នមត្ថុ រតនត្តយស្ស

សូមនមស្ការថ្វាយបង្គំ បំពោះព្រះរតនត្រ័យ គឺ: ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ ដោយសេចក្ដីគោរព ។

លំដាប់អំពីបទនមស្ការនេះទៅ, អាត្មាភាពសូមសំដែងអំពីអបាយមុខ ៦ យ៉ាង ដែលសម្ដេចព្រះសព្វញ្ញុពុទ្ធទ្រង់ទេសនាប្រារព្ធបំពោះសិង្គាលមាណព ក្នុងគម្ពីរទីឃនិកាយ ត្រង់សិង្គាលោវាទសូត្រ ដូចសេចក្ដីតទៅនេះ :

អបាយមុខ ប្រែថា: "ហេតុជាប្រធាននៃសេចក្ដីវិនាស" ។ អ្នកដែលបានប្រព្រឹត្តអបាយមុខនេះ នឹងជួបសេចក្ដីវិនាសឃើញទាន់ហន់ក្នុងលោកនេះ ។ អបាយមុខនោះមាន ៦ យ៉ាង គឺ:

**១ — ការផឹកទឹកស្រវឹងគឺសុរានឹងមេរ័យ** — សុរានឹងមេរ័យនេះ ជាទឹកសម្រាប់បំពុល ឬ សម្រាប់បង្វិលចិត្តមនុស្សឲ្យខុសប្រក្រតី ។ មនុស្សអ្នកក្រេបលេបទឹកស្រវឹងចូលទៅហើយ, ទឹកនេះអាចកំដៅហទយ:

គឺបេះដូងឲ្យញាប់ញ័រ ច្រើនតែបណ្ដាលឲ្យកើតសេចក្ដីក្លាហានព្រហើន-កោងកាចប្រមាថមើលងាយអ្នកដទៃ, អំពើខុសយល់ថាជាត្រូវ, អំពើត្រូវយល់ថាជាខុសវិញ ។ មនុស្សខ្លះបើមិនទាន់ត្រូវសុរាចូលទៅដល់ទេ តែងមានបុគ្គលភាពសុភាពរាបសា ដឹងខុសត្រូវគួរសម, តែវេលាណាត្រូវសុរាហើយ អំណាចសុរានេះបង្វិលចិត្តឲ្យខុសប្រក្រតីមួយរំពេច គឺបញ្ចេញអាការៈថោកទាបដោយផ្លូវកាយនិងវាចា, ទៅជាមនុស្សប្រឆេងប្រឆាំងទ្រាក់ទ្រើកញញាក់ញញ័រ ទាំងសំដីសោតទៀតក៏និយាយច្រំដែលៗ មិនទៅមុខ ចេញលំនាំប្រហែលគ្នានឹងមនុស្សឆ្កួត ។ មនុស្សប្រមឹកញៀនសុរានេះ រមែងទទួលរងទុក្ខទោសគ្រោះថ្នាក់ ៦ យ៉ាង អាចឃើញជាក់ច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្នជាតិនេះគឺ :

ក) អ្នកប្រមឹកសុរា តែងចាយវាយទ្រព្យសម្បត្តិកញ្ជះកញ្ជាយ, យកទៅទិញដូរសុរាខ្លះ សាច់ខ្លះ ឬរបស់អ្វីឯទៀតខ្លះ សម្រាប់ក្លែមជា-មួយនឹងសុរា; អ្នកខ្លះថាស៊ីផឹកតែម្នាក់ឯងមិនសូវឆ្ងាញ់មិនសូវសប្បាយទេ, លុះតែមានគ្នាទើបហ៊ឺហាសប្បាយ, ម្ល៉ោះហើយក៏ហៅរកបបួលមនុស្សណាដែលមានចរិយាថោកទាបដូចខ្លួនដែរមកស៊ីផឹកជាមួយ ។ អ្នកប្រមឹកសុរាបែបនេះ គ្មានពេលឱកាសនឹងធ្វើការស្វែងរកទ្រព្យសម្បត្តិទេ, មានតែផ្លូវចាយវាយបំផ្លិចបំផ្លាញតែម្យ៉ាង, កាលបើប្រាក់កាសសម្រាប់ចាយធម្មតាមិនគ្រប់គ្រាន់ទេ, ក៏គោងលក់ផ្ដាច់ឬបញ្ចាំគ្រឿងមរតក មានផ្ទះ

សម្បែងដីស្រែចំការច្បារដំណាំជាដើម ដកបទាល់តែអស់រលីង, ក៏តាំង សំគុកកើតទុក្ខមុខស្ងួតអស់ទាំងគ្រួសារ ធ្លាក់ខ្លួនទៅជាមនុស្សអនាថាឥត ទីពឹង ត្រេះត្រោមរហាម ក្លាយទៅជាចោរលួចចោរប្លន់ក៏មាន ។

ខ) អ្នកប្រមឹកសុរា ពេលណាស្រវឹងស៊ប់ហើយ ក៏តាំងបង្កហេតុ រករឿងឈ្លោះជេរប្រទេចប្រពន្ធកូនឯង; បើរករឿងប្រពន្ធកូនរបស់ខ្លួនមិន បានទេ, ក៏បែរទៅរករឿងឈ្លោះនឹងរបស់ប្រើប្រាស់ មានពាងចានទឹង ឆ្នាំងជាដើម វាយសំពងខ្ទេចខ្ទីបែកបាក់អស់ក៏មាន, បើមិនដូច្នោះទេ, បង្កហេតុរករឿងអ្នកផងជិតខាង គេអត់មិនបានក៏កើតទៅជាជេរតបតវាយ ដំគាប់ចាក់គ្នាទៅវិញទៅមក ជាប់គុកច្រវាក់បង់ទ្រព្យថែមទៀតក៏មាន ។

គ) អ្នកប្រមឹកសុរា ឈ្មោះថាជាអ្នកបង្ករោគផ្សេងៗ ឲ្យកើតចំរើន នៅក្នុងរាងកាយរបស់ខ្លួន មានរោគងឹតក្អែក ខូចក្រពះពោះវៀន ខូចសួត ជាដើម ឆាប់ចាស់ជរាអាយុខ្លី ដោយអំណាចសុរាក៏មាន ។

ឃ) អ្នកប្រមឹកសុរា មានកិត្តិសព្ទកេរ្តិ៍ឈ្មោះមិនល្អ ជាទីខ្ពើម រអើមរបស់ពួកសប្បុរស, ទាំងសំដីនិយាយកិច្ចការអ្វីសោតទៀត គេ ក៏មិនសូវជឿស្តាប់មិនយកជាប្រមាណ, បើទុកជាមានកូនកំឡោះក្រមុំច្បង ច្រាង គេក៏មិនត្រូវការ ថែមទាំងគេជេរលថា "ពូជប្រមឹកសុរាកុំចូលទៅ ជិត, នាំឲ្យសៅហ្មងដល់ពូជពង្សត្រកូលរបស់យើង" យ៉ាងនេះក៏មាន ។

ង) អ្នកប្រមឹកសុរា វេលាស្រវឹងស៊ប់ហើយ គត់មានសេចក្តីអៀន ខ្មាសទេ, អវយវៈដែលគេត្រូវលាក់បិទបាំង ខ្លួនឯងទៅជាសើយលាត

បញ្ចេញអាការកិរិយាឲ្យគេឃើញជាក់ស្តែង, ជួនកាលដើរស្រែករៀវៗ ប៉ប៉ាច់ប៉ប៉ោចតាមផ្លូវដូចឆ្កួត សំដែងអាការថោកទាបក៏មាន, ខ្លះស្រវឹងក្អួតដួលដេកស្ពឹងស្តូកហាក់ដូចស្លាប់ តាមបន្ទោះផ្លូវ ឬសំយាបផ្ទះគេក៏មាន, មិនតែប៉ុណ្ណោះ ចិត្តធំព្រហើនហ៊ានកាប់សម្លាប់ឥតកោតញញើតយ៉ាងនេះក៏មាន ។

ប) អ្នកប្រមឹកស្រា ឈ្មោះថាជាអ្នកធ្វើបំណេះវិជ្ជាព្រមទាំងប្រាជ្ញាស្មារតីឲ្យអន់ថយខ្សោយចុះទៅជាជាប, បើនឹងគិតការអ្វីឬធ្វើការអ្វី ច្រើនធ្វើប្រហុយទៅទាំងកំពេលឥតដឹងខុសត្រូវ ។

អ្នកប្រមឹកស្រាមិនមែនធ្វើឲ្យថោកត្រឹមតែខ្លួន ១ ឬត្រកូលរបស់ខ្លួន ១ ទេ, បានឈ្មោះថាធ្វើជាតិនឹងប្រទេសឲ្យថោកថែមទៀត ។ ហេតុនេះ, អស់លោកអ្នកកាន់អំណាច គួរតែផ្ចាញ់ផ្ចាលបំបាត់សភាពប្រមឹកបែបនេះក្នុងស្រុកនីមួយៗកុំឲ្យមាន ទើបនឹងមានសេចក្តីចំរើន ។

សេចក្តីដែលបានពណ៌នាមកនេះឈ្មោះថា អបាយមុខទី ១ ។

**២ – ការដើរលេងក្នុងវេលាយប់ខុសកាល** – ពេលដែលគេត្រូវសម្រាកសម្ងំដេកពួន ខ្លួនដើរលេងដេកមមកតាមច្រកល្ហកផ្លូវតូចធំហួសពេលវេលា បោលប្រពន្ធកូនទ្រព្យសម្បត្តិនៅឯផ្ទះ ឥតមានអ្នកណាគ្រប់គ្រងរក្សា ឈ្មោះថាបើកឱកាសឲ្យដល់សត្រូវគឺចោរប្រមាថមើលងាយដល់ទ្រព្យសម្បត្តិក៏មាន, ជួនកាលខ្លួនឯងដើរលេងទៅក៏ត្រូវ

ទទួលគ្រោះថ្នាក់ មានពស់ក្អែបខាំទិចជាដើមក៏មាន, ពុំនោះសោត មានអ្នកផងគេវង្កៀសសង្ស័យថា អ្នកនេះហៃដើរពេលយប់ ប្រហែលជាអ្នករកស៊ីដោយផ្លូវទុច្ចរិតទេដឹង?, ជួនកាលមានចោរលួចឆក់ទ្រព្យសម្បត្តិរបស់គេពិតហើយរត់គៀសគេចខ្លួនបាត់ទៅ, ទទួលគេឃើញខ្លួនដើរទៅ, ម្ចាស់ទ្រព្យគេក៏ចោទប្រកាន់ខ្លួនថាជាចោរ ហើយក៏នាំគ្នាចាប់ចងធ្វើទុក្ខទោស ដាក់ពិន័យជាប់គុកច្រវាក់បង់ទ្រព្យធនធានក៏មាន ។ នេះឈ្មោះថា អបាយមុខទី ២ ។

**៣ – ការដើរមើលល្បែងមហោស្រពផ្សេងៗ –** បុរសក្តី ស្ត្រីក្តី កាលបើដឹងឮថាល្បែងប្រៀងកំពុងកំប្លែង មាននៅកន្លែងណា ក៏ដើរចូលទៅកាន់ទីនោះ ហើយស្តាប់ឬមើលល្បែងនោះៗ ដោយសេចក្តីសប្បាយជាប់ចិត្តភ្លេចខ្លួនឥតនឹកនាដល់ប្រពន្ធកូន ឬប្តីសីទ្រព្យសម្បត្តិដែលមាននៅក្នុងផ្ទះ, មិនតែប៉ុណ្ណោះ ខាតទាំងប្រាក់កាសដែលត្រូវចាយក្នុងល្បែងនោះៗផង, ខាតទាំងពេលដេកអត់ងងុយផង, ខាតទាំងពេលដែលត្រូវប្រកបការងាររកស៊ីផង ។ ធម្មតាអ្នកមើលល្បែងមិនអាចធ្វើចិត្តឲ្យស្ងប់ស្ងាត់បានទេ, ឈ្មោះថាជាអ្នកពន្លឹកបណ្តែតបណ្តោយចិត្តឲ្យរវើរវាយរត់ទៅក្នុងកាមគុណកាន់តែខ្លាំងឡើងៗ, ជួនកាលប្រុសលះលែងប្រពន្ធរបស់ខ្លួនរត់ទៅតាមស្រីអ្នកលេងល្បែងក៏មាន, ជួនកាលស្រីលះលែងប្តីរបស់ខ្លួន រត់ទៅតាមប្រុសអ្នកលេងល្បែងក៏មាន,

ចំណែកប្រុសលបលាក់យកទ្រព្យរបស់ទៅឲ្យស្រី, ចំណែកស្រីលបលាក់យកទ្រព្យរបស់ទៅឲ្យប្រុស ។ រឿងទាំងនេះក្នុងសម័យបច្ចុប្បន្នឥឡូវសឹងមានជាច្រើននៅស្រុកក្រៅនិងទីក្រុង, បើបុរសឬស្ត្រីមានសភាពយ៉ាងនោះ ដែលជាអ្នកមានអំណាច កាលបើប្រាក់កាសសម្រាប់ចាយចាត់ចែងមិនគ្រប់គ្រាន់ទេ ក៏តាំងប្រើឧបាយកលសង្កត់សង្កិនដោយផ្លូវអយុត្តិធម៌ ឥតអាណិតអាសូរដល់អ្នកផង ដើម្បីយកទៅបង្គ្រប់បំប៉នកាមគុណទាំងនោះ ។ រឿងនេះគួរឲ្យសង្វេគ គួរឲ្យនឹកស្តាយពេកណាស់. បើប្រសិនជាយកចិត្តទុកដាក់ទំនុកបម្រុងស្រុកទេស ឲ្យបានប្រហែលគ្នានឹងយកចិត្តទុកដាក់ក្នុងមាតុគ្រាមវិញ, ស្រុកទេសមុខតែនឹងបានសេចក្តីចំរើនថ្កុំថ្កើងទាន់សម័យមិនខាន ។ សេចក្តីដែលបានពណ៌នាមកនេះឈ្មោះថា អបាយមុខទី ៣ ។

**៤ ការលេងល្បែងភ្នាល់ស៊ីសង** - ល្បែងភ្នាល់ស៊ីសងនេះមានច្រើនយ៉ាង រាប់តាំងពីបៀនិងឆ្នោតជាដើមទៅ ។ បុរសស្ត្រីអ្នកចូលចិត្តប្រព្រឹត្តលេងល្បែងស៊ីសងឯណានីមួយ សុទ្ធតែមានបំណងចង់បានប្រយោជន៍ចំណេញមកឆាប់ៗ, ប៉ុន្តែហេតុការណ៍ពិតនោះ មិនមែនត្រូវដូចគំនិតដែលប៉ងនោះទេ, បើទុកជាត្រូវបំណងខ្លះក៏មានតិចណាស់ក្នុងលោកនេះ; គួរអស់លោកអ្នកពិចារណាមើលដូច្នេះថា អ្នកមានភោគសម្បទច្រើនរាប់ម៉ឺនរាប់សែននៅជុំវិញខ្លួនសព្វថ្ងៃនេះ តើគេមានមកអំពី

លេងល្បែង ឬគេមានមកអំពីប្រកបកសិកម្មនិងពាណិជ្ជកម្ម? ។ ធម្មតាអ្នកប្រព្រឹត្តលេងល្បែងភ្នាល់, មិនដែលអ្នកណាមួយមានកំណើតទៅជាមនុស្សគ្រាន់បើទេ, ច្រើនតែទទួលរងគ្រោះថ្នាក់សេចក្ដីវិនាសច្រើនប្រការគឺ: អ្នកប្រព្រឹត្តលេងល្បែង កាលបើខ្លួនឈ្នះក៏ប្រើអំណាចរំលោភអូសយកទ្រព្យសម្បត្តិអំពីអ្នកចាញ់ៗ ក៏កើតសេចក្ដីក្ដៅក្រហាយចងពៀរព្យាបាទគ្នាទៅវិញទៅមកក៏មាន, អ្នកចាញ់តែងដេកកើតទុក្ខបរដកដង្ហើមធំស្ដាយទ្រព្យសម្បត្តិ ដែលវិនាសបាត់ទៅរហូតដល់លែងចង់រស់នៅជាមនុស្ស ដោយប្រើវិធីចងកសម្លាប់ខ្លួនឯងជាដើមក៏មាន, អ្នកលេងល្បែងច្រើនមានឧបាយកុហកកូតករបោកប្រាសគេឲ្យតែបានដល់ដៃ ឬទោះបីទៅនិយាយពឹងពាក់ប្រស្រ័យកិច្ចការអ្វី ៗ នឹងគេ ៗ ក៏មិនជឿមិនយកជាប្រមាណ ម្ល៉ោះហើយក៏ធ្លាក់ខ្លួនទៅជាមនុស្សថោកឥតគេត្រូវការរាប់រក ៗ ម្យ៉ាងទៀត ល្បែងស៊ីសងអស់នេះច្រើនធ្វើទុក្ខដល់អ្នកនៅទំនេរ, ដូចកាលប្ដីទៅធ្វើការបាត់ ប្រពន្ធនៅផ្ទះទំនេរឥតការអ្វីធ្វើ ក៏តាំងរៃក្នុងតទល់នឹងប្រុសៗ ឬនឹងស្រីៗ ដូចគ្នា តាំងពីព្រលឹមទល់ថ្ងៃត្រង់ តាំងពីបែរពីថ្ងៃត្រង់ទល់ល្ងាច, ដូចកាលក៏ចាញ់អស់រលីងពីខ្លួន ហើយក៏តាំងលក់ឬបញ្ចាំគ្រឿងអលង្ការ សម្រាប់តាក់តែងរាងកាយយកមកលេងទៀត, កាលណាប្ដីដឹងក៏កើតទៅជាឈ្លោះទាស់ទែងលែងលះគ្នាក៏មាន ។ នេះឈ្មោះថាអបាយមុខទី ៤ ។

**៥ – ការសេពគប់នឹងបាបមិត្រ** — មនុស្សណាដែលប្រព្រឹត្តធ្វើនូវអំពើអាក្រក់ ជាហេតុនាំឲ្យកើតសេចក្ដីវិនាសដល់ខ្លួនឬដល់អ្នកដទៃ, មនុស្សនោះគេហៅថាបាបមិត្រ ។ បើអស់លោកអ្នកចង់ស្គាល់ថាមនុស្សបែបណាជាបាបមិត្រនោះ តោងពិនិត្យសង្កេតដោយផ្លូវកាយ - វាចានិងចិត្ត ក៏នឹងអាចដឹងបាន ។ បណ្ដាមនុស្សក្នុងលោក, អ្នកណាមួយទោះជាមនុស្សជាន់ខ្ពស់ក្ដី ជាន់កណ្ដាលក្ដី ជាន់ទាបក្ដី សុទ្ធសឹងតែមានការងារត្រូវធ្វើជាប្រក្រតី, បើមនុស្សសប្បុរសល្អ ការងារចេញមកតាមផ្លូវកាយក៏ល្អ ចេញមកតាមផ្លូវវាចាក៏ល្អ ចេញមកតាមផ្លូវចិត្តក៏ល្អ; មិនតែប៉ុណ្ណោះ រឹថែមទាំងជាអ្នកមានករុណាអាណិតអាសូរចំពោះអ្នកដទៃជានិច្ច, ធ្វើការអ្វីមិនអាងយសស័ក្តិ មិនអាងអំណាច មិនលំអៀងព្រោះស្រឡាញ់ ព្រោះស្អប់ ព្រោះខ្លាចទេ; មនុស្សបែបនេះហៅថាកល្យាណមិត្រ, គួរសេពគប់រាប់រកយកជាមិត្រសំឡាញ់ ។ មនុស្សណាជាអ្នកប្រព្រឹត្តលេងល្បែងភ្នាល់ស៊ីសង, ជាអ្នកលេងស្រី, ជាអ្នកលេងផឹកសុរា, ជាអ្នកបញ្ឆោតបោកប្រាសអ្នកដទៃដោយឧបាយកលណាមួយ, ជាអ្នកប្រើអំណាចរំលោភសង្កត់សង្កិនអ្នកដទៃ ដោយអាងយសស័ក្តិឬដោយអាងទ្រព្យសម្បត្តិ មនុស្សបែបនេះហៅថាបាបមិត្រ, កុំចូលទៅសេពគប់រាប់រកយកជាមិត្រសំឡាញ់ឡើយ ។

សេចក្ដីដែលពណ៌នានេះ ចាត់ជាអបាយមុខទី ៥ ។

**៦ – ការខ្ជិលច្រអូស** – សេចក្ដីខ្ជិលនេះ បើមាននៅលើរូបបុគ្គលណាហើយ អាចនឹងពន្ធិចបន្ទាបបុគ្គលនោះ ឲ្យធ្លាក់ទៅជាមនុស្សក្រីក្រល្ងង់ខ្លៅ មិនមានចំណេះវិជ្ជានឹងភោគសម្បទ ៗ ធម្មតាមនុស្សដែលលុះក្នុងអំណាចនៃសេចក្ដីខ្ជិល បើនឹងធ្វើការអ្វីឬរៀនចំណេះអ្វីច្រើន ច្រើអាការទម្រន់ដោយយកអ៊ីម្យ៉ាងៗ មកធ្វើជាលេសគ្រឿងអាងរបស់ខ្លួន គឺអ្នកខ្លះអាងថា ថ្ងៃនេះនៅព្រឹកណាស់, ល្ងាចណាស់, ត្រជាក់ណាស់, ក្ដៅណាស់, ឃ្លានណាស់, ស្រេកណាស់ ធ្វើការឬរៀនអ្វីពុំទាន់កើតទេ ចាំសម្រាកខ្លួនឬចាំបរិភោគអ្វីបន្តិចសិន សឹមធ្វើការឬសឹមរៀន; ការទម្រន់ខ្ជិលបែបនេះហើយ ដែលជាប្រធានធ្វើបុគ្គលនោះ ឲ្យដល់នូវភាពជាមនុស្សថោកទាបឥតគេត្រូវការរាប់រក ៗ ម្យ៉ាងទៀតអស់លោកអ្នកដែលជាមេបា ក្នុងគ្រួសារឬក្រុមមួយ ៗ ខ្លះមិនសូវប្រឹតប្រៀនរំលឹកដាស់តឿនកូនចៅឬអ្នកដែលនៅក្រោមបង្គាប់របស់ខ្លួន ឲ្យខំប្រឹងធ្វើការឬឲ្យខំប្រឹងរៀនតាមមុខការរបស់វាទេ, ច្រើនតែបណ្ដោយបណ្ដោយឲ្យក្មេងនៅទំនេរខ្ជិលដើរលេងតាមអំពើចិត្ត, លុះយូរទៅក៏ក្លាយទៅជាមនុស្សល្ងង់ខ្លៅខ្សត់ខ្សោយចំណេះវិជ្ជានឹងភោគសម្បទ, មិនតែប៉ុណ្ណោះ មនុស្សល្ងង់ឈ្មោះថាធ្វើជាតិត្រកូលនឹងស្រុកទេសឲ្យថោកទាបថែមទៀត ៗ សូមអស់លោកអ្នកពិនិត្យសង្កេតមើលទោសរបស់មនុស្សខ្ជិល សព្វថ្ងៃនេះចុះ, នៅក្នុងក្រុងឃើញមាននៅដេរដាសទាំងស្រីទាំងប្រុស, ខ្លះដេកដើរឈរអង្គុយរជូករណែលក្រោមម្លប់ឈើ ឬតាម

សំយាបផ្ទះ ក្បែរបិតញ្ញមជ្ឈល់, រកស៊ីគ្រាន់តែឲ្យរស់ត្រឹមមួយថ្ងៃៗប៉ុណ្ណោះ, បើទឹងធ្វើការគត់មានទុប្បាយគំនិតណា ថាអញត្រូវធ្វើយ៉ាងនេះយ៉ាងនោះទើបល្អដូច្នេះសោះឡើយ, មនុស្សបែបនេះហើយ ដែលសំដែងអាការឲ្យឃើញថោកទាបដល់ជាតិទឹងស្រុកទេស ។ នេះឈ្មោះថាអបាយមុខ ទី ៦ ។

មនុស្សខ្ជិលដូចបានពណ៌នាមកទាំងនេះ ប្រសិនបើកជការបង្កើតរបរការអ្វីមួយ ដើម្បីតម្រូវដល់មនុស្សទាំងនេះឲ្យមានការធ្វើឡើង គទៅប្រហែលជានឹងមានសេចក្តីចំរើនដល់រាជការវិញពុំខាន ។

អាត្មាភាពសំដែងអំពីអបាយមុខទាំង ៦ យ៉ាង ចប់ត្រឹមតែប៉ុណ្ណេះ ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ ទាណិនោ ។

សត្វសត្វដែលដល់ហើយនូវទុក្ខ សូមឲ្យបាត់ទុក្ខទៅ ! ដែលដល់ហើយនូវភ័យ សូមឲ្យបាត់ភ័យទៅ ! ដែលដល់ហើយនូវសោក សូមឲ្យជាអ្នកបាត់សោកទៅ ! ។

ធម្មទេសនាតេជេន កាលេ វស្សន្តុ មេឃា
វុឌ្ឍិ វិរុឡ្ហិ បប្បោន្តុ សទ្ធិការញ្ច ជាតិយា ។

ដោយអំណាចនៃព្រះធម្មទេសនា (នេះ) សូមឲ្យប្រជាជនទាំងឡាយអ្នកនៅក្នុងកម្ពុជរដ្ឋ ដល់នូវការលូតលាស់ចំរើនទឹងសន្តិភាព កុំបីឃ្លាតឆ្ងាយទៅជាប្រការដទៃឡើយ ! ។

# ព្រះមហាឧត្តមវិជ្ជា ផលញាណោ ប៉ុង-ប៉ម

អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

## ឧបាយបណ្ដុះនិស្ស័យទី ២

## និស្ស័យសុភាព

អស់លោក-អ្នកសុភាពទាំងឡាយ ! ពាក្យថា "បុរសសុភាព ស្ត្រីសុភាព" នេះ យើងគង់ធ្លាប់បានឮស្ទើរតែរៀមត្រចៀកមកហើយ ៗ តែទោះបីដូច្នោះ ក៏សូមកុំភ្លេចថា "បុរសដែលសុភាពឬស្ត្រីដែលសុភាព នោះមិនមែនព្រោះអ្វីទេ គឺព្រោះតែគេជាមនុស្សល្អ មាននិស្ស័យសុភាព នៅក្នុងខ្លួន" ៗ បើលក្ខណៈសុភាព មិនមានជាប់នៅក្នុងខ្លួនទេ ក៏គេនឹងទៅជាមនុស្សសុភាពមិនបានឡើយ ៗ ព្រោះមនុស្សនិស្ស័យសុភាព ត្រូវមានសេចក្ដីសុភាពរៀបរយនៅក្នុងខ្លួនសន្ដាន ទាំងសំដែងកិរិយានឹងពោលចេញមកទៀត ក៏ជាទីនិយមរាប់អាននៃមនុស្សទូទៅ ៗ មិនត្រឹមតែសំដែងអាការកាយ-ពោលឲ្យឃើញថាមានកិរិយាទន់លំទោន និយាយពីរោះផ្អែមល្ហែម នឹង មានទឹកមុខរីករាយស្រស់ស្រាយញញឹមញញែម

ប៉ុណ្ណោះឡើយ សូម្បីផ្លូវចិត្តក៏នៅតែខ្ជាប់ខ្ជួនក្នុងលក្ខណៈនៃការសុភាព នោះដែរ ។

មើលចុះ! មនុស្សសុភាពយើងធ្លាប់ឃើញមកហើយ នឹងឃើញប្រត្យក្សច្បាស់លាស់តទៅទៀត ដោយអាការគោរពទន់លំទោនជានិច្ច ប្រើកិរិយានឹងវាចាចំពោះអ្នកតូច ដូចគ្នានឹងប្រតិបត្តិចំពោះអ្នកធំ មិនលើកតំកើងខ្លួន សូម្បីក្នុងករណីយកិច្ចណា ៗ ទាំងអស់ ៗ ឯមនុស្សមិនសុភាពវិញ សូម្បីធ្វើត្រាប់និយាយពីរោះ ក៏គង់មានរឿងអ្វីមួយ នាំឲ្យខុសប្លែកពីមនុស្សដទៃ ៗ យើងអាចដឹងបានដោយសារអ្នកនោះ នៅខ្វះសេចក្តីល្អដទៃទៀតជាច្រើន ៗ ព្រោះមនុស្សមិនសុភាពនោះ សូម្បីមានគុណគឺសេចក្តីល្អក្នុងផ្លូវដទៃនៅក្នុងខ្លួនខ្លះ ក៏គង់ធ្វើឲ្យគេកើតសេចក្តីនិយមជ្រះថ្លានឹងគោរពរាប់អានមិនបាន ៗ

កាលបើយើងមានធម៌សុភាពនៅក្នុងខ្លួនហើយ ក៏អាចធ្វើឲ្យអ្នកដទៃកើតសេចក្តីត្រេកអរ ស្រឡាញ់ គោរពរាប់អាន ដោយសុទ្ធចិត្តពិត ៗ បាន ៗ បើគ្មានសេចក្តីសុភាពវិញ ក៏មិនអាចធ្វើឲ្យគេមានសេចក្តីនិយមរាប់អាន ក្នុងកិរិយានឹងវាចារបស់យើង សូម្បីតែបន្តិចបន្តួចបានទេ, នេះព្រោះតែការមិនសុភាពនោះចូលមកជ្រៀតជ្រែក បណ្តាញយើងឲ្យឆ្ងាយចាកមនុស្សដទៃ ទាំងហាមមនុស្សដទៃមិនឲ្យចូលមកទាក់ទងនឹងយើង ឈ្មោះថាយើងមានឫសគល់ដែលជាគ្រឿងច្រានខ្លួនឲ្យធ្លាក់ទៅ

កាន់ទីតាំងគ្រប់វេលា ។ "បើយើងមានលក្ខណៈទន់ដែងនៅក្នុងខ្លួនហើយ យើងនឹងទៅជាមាសពុំបានឡើយ" នេះជារឿងដែលត្រូវនឹករឭកជានិច្ច ។

ការប្រព្រឹត្តល្អប្រពៃ តាមក្របខ័ណ្ឌនៃមនុស្សធម៌ ជាលក្ខណៈនៃសេចក្ដីសុភាព ។ មនុស្សសុភាព គឺមនុស្សប្រព្រឹត្តល្អតាមរបៀបនៃមនុស្សធម៌ មានអធ្យាស្រ័យទឹកចិត្តល្អត្រជាក់ត្រជុំ ស្គាល់ចិត្តថ្លើមរបស់មិត្តភក្កិកង្វះហូតដល់មិត្តភក្កិងសាកលលោក សំដែងកិរិយានិងពាក្យសម្ដីគួរសម ទំនងបំពោះមុខអ្នកធំ ទំនងបំពោះមុខអ្នកតូចមិនប្រងើងប្រង៉ាង មិនរឹងរូស ។ បើជាអ្នកធំវិញ ក៏មិនជ្រៀតជ្រៀតអ្នកតូច ។ សូម្បីជាអ្នកតូច ក៏មិនព្រហើនកោងកាចបំពោះអ្នកធំ ប្រើសំដីអនុកូលដល់គ្នានឹងគ្នា មិនយកឈ្នះយកប្រៀបគ្នា ។ បើពោលដោយខ្លីទៅ ខ្លឹមសារនៃការសុភាពនោះ នៅត្រង់សេចក្ដីល្អ ។ មនុស្សសុភាព ក៏គឺមនុស្សល្អនោះឯង ។ មនុស្សល្អនោះ មិនមែនល្អព្រោះវិការៈនៃរាងកាយល្ងាសល្ងន់ មិនមែនល្អព្រោះរូបសម្បត្តិ មិនមែនល្អព្រោះជាតិត្រកូលឬទ្រព្យសម្បត្តិឡើយ គឺល្អព្រោះតែអ្នកនោះមានសេចក្ដីល្អនៅក្នុងខ្លួន ។ និយាយ ១ ជាន់ទៀតថា សេចក្ដីល្អដែលនៅក្នុងខ្លួនដែននៃការសុភាពនេះ គឺកិរិយាសុភាព វាចាសុភាព និងចិត្តសុភាព ។ អ្នកមានកិរិយាសុភាព, មានវាចាសុភាព និងមានចិត្តសុភាពនោះឯង ជាមនុស្សសុភាព ។

**កិរិយាសុភាព** – "កិរិយា" សំដៅយកអាការដែលសំដែងចេញប្រាកដមកដល់អ្នកដទៃ ៗ កិរិយានេះ សូម្បីត្រឹមតែជាអាការខាងក្រៅក៏ពិតមែន តែគង់ជាវត្ថុយ៉ាងសំខាន់ក្រៃលែង ព្រោះជាកាសែតសម្រាប់បើកផ្លូវឬបិទផ្លូវរបស់ជីវិត ទាំងជាគ្រឿងប្រដាប់នៃការធ្វើ នឹងការនិយាយផង ៗ ដ្បិតថា កាលបើយើងធ្វើសេចក្ដីអាណិតអាសូរករុណាប្រណីនិយាយពាក់ទាក់ផ្អែមល្ហែម ឬធ្វើសេចក្ដីអាក្រក់ផ្សេងៗ និយាយពាក្យអាក្រក់គ្រោតគ្រាតគំរោះគំរើយហើយ កិរិយានោះគង់បំពេញផលល្អឬផលអាក្រក់តាមតែអំពើដែលយើងធ្វើនោះ ឲ្យមានកំឡាំងឡើងអាចបើកបង្ហាញនូវនិស្ស័យចិត្តដល់អ្នកដទៃបាន គឺបង្ហាញសេចក្ដីគាប់ចិត្ត សេចក្ដីស្រឡាញ់ សេចក្ដីបេះដូង សេចក្ដីត្រេកអរ ឬសេចក្ដីក្រោធ ៗ ល ៗ ដែលចេញមកពីខាងក្នុងខ្លួនឲ្យប្រាកដដល់អ្នកដទៃល្មមឲ្យគេដឹងបានថា ជាកិរិយាល្អ ឬកិរិយាអាក្រក់ ៗ

អស់លោកអ្នកប្រាថ្នាសុខទាំងឡាយ ! កិរិយាអាការខាងក្រៅដូចជាការយាត្រា ការឱនលំទោន ការនិយាយអភិប្រាយ ការធ្វើភ្នែកឬធ្វើមាត់ ជាគំនូសឲ្យយើងស្ទង់ដឹងដល់ចិត្តគ្នាបាន ដូចក្នុងបុរាណភាសិតថា "សំឡេងប្រាប់ភាសា កិរិយាប្រាប់ត្រកូល" ៗ សូម្បីក្នុងលោកនីតិក៏មានពោលដែរថា

"ប្រមាណជម្រៅទឹកពិនិត្យ ឲ្យដកព្រលឹតវាស់វែងវា
ប្រមាណត្រកូលអ្នកកាចដា ឲ្យមើលកិរិយាអាការចេញ ៗ

ប្រមាណអ្នកឈ្លាសវៃប្រាជ្ញប្រាយ មើលកាលនិយាយពោលមកមិញ
ប្រមាណប្រថពីដីរដីដេញ មើលស្មៅខៀវចេញកាត្រកល្អ ។

**កិរិយាល្អ, កិរិយារម្យទម និងកិរិយាឱនលំទោន** សម្រាប់ប្រាប់ផ្លូវរបស់ជីវិតឲ្យប្រាកដប្រជា ទាំងធ្វើឲ្យការសមាគមជិតស្និទ្ធចូលគ្នាបាន នេះជាលក្ខណៈនៃកិរិយាសុភាព ។

មនុស្សសុភាព សូម្បីធ្វើការអ្វីត្រឹមតែបន្តិចបន្តួច ក៏គួរជាទីរីករាយ ជាទីនិយម ជាទីរាប់អាន ជាទីរមិលមើលនៃជនដទៃ ព្រោះអំពើនោះសុទ្ធតែជាគ្រឿងបើកផ្លូវឲ្យជីវិតធ្វើដំណើរទៅដោយសួស្តីទាំងអស់ ។ ចំណែកមនុស្សមិនសុភាពវិញ សូម្បីធ្វើការអ្វីដែលជាអង្គនៃសេចក្តីល្អ ក៏គង់ជាគ្រឿងទើសភ្នែក ទើសត្រចៀក ទាស់ចិត្តនៃមនុស្សដទៃដែរ ព្រោះជាហេតុធ្វើគន្លងផ្លូវនៃការងាររបស់ខ្លួនឯង ឲ្យខុសស្រឡះទៅទាំងស្រុង ។

**ក) កិរិយាល្អ**— កិរិយាល្អឬមិនល្អនោះ នៅត្រង់កាលៈទេសៈ ។ លោកក្នុងសម័យមុន រមែងនិយមការល្វាសល្វន់ ទន់ភ្លន់ យាងយាសកៃក្រោយ ថាជាកិរិយាល្អ ។ តែលោកក្នុងបច្ចុប្បន្ននេះ ត្រឡប់យល់ឃើញកិរិយាយ៉ាងនោះថាជាកិរិយាយឺត កិរិយាប្រអុស កិរិយាញ៉ុកញ៉ក់ មិនគួរមើលទៅវិញ ។ ពិតមែន បើយើងពិចារណាហេតុក្នុងសម័យនេះហើយ ក៏គង់ឃើញបានថាសេចក្តីល្អ មិនមែននៅត្រង់ការយាងយាស

នោះទេ ។ អ្នកណាមិនបានឈានជើងដោយអាការដ៏រហ័សរហួនហើយ អ្នកនោះ នឹងត្រូវគេតិះដៀលថាជាមនុស្សយឺត មនុស្សប្រហូស ។ អ្នកប្រាជ្ញខាងវិទ្យាសាស្ត្របានពោលថា "កិរិយាយាងយាសកៃក្រោយនោះ ជាហេតុឲ្យយឺត ការយឺតជាហេតុឲ្យរាងកាយមិនមានកំឡាំងល្មមដល់សេចក្ដីបំណងរបស់ធម្មជាតិ ជាសម្ពាធឲ្យកើតរោគភ័យឈឺ ចាប់ នឹងអាយុខ្លី" ។ សូម្បីអ្នកប្រាជ្ញខាងផ្លូវចិត្ត ក៏មានមតិត្រូវគ្នាថា "កាយយឺត ចិត្តក៏យឺត, ចិត្តយឺតជាចិត្តដែលទន់ខ្សោយ, ឯចិត្តដែលទន់ខ្សោយនោះគឺចិត្តដែលមិនអង់អាច ជាចិត្តធ្វើអ្វីមិនសម្រេច" ។

កិរិយាល្អដែលលោកនិយមក្នុងសម័យអារ្យៈ នៅត្រង់កិរិយាប្រញាប់ប្រញាល់រហ័សរហួន មានរាងកាយស្វាហាប់ បានរូបរាង បានទ្រង់ទ្រាយយ៉ាងខែងរ៉ែង ។ កិរិយាល្អមិនមែននៅត្រង់កិរិយាយាងយាសកៃក្រាយល្វាសល្វន់ មិតពត់ប្តូរជើយស្ទើន មិនសមនឹងដំណើរទំនងនោះទេ ។ បើទុនក៏មិនទុនតែក្បាលក្អកនោះដែរ គឺទុនលំទោនដែលប្រកបព្រមដោយការរឹងប៉ឹងអង់អាចនឹងខែងរ៉ែងគួរមើល ។ ឯកិរិយាដែលល្អនោះសោតត្រូវឲ្យសមគួរដល់បុគ្គល ដល់ទីឋាន នឹងដល់កាលសម័យផង ។ គ្រប់តែពេលដែលយើងសំដែងកិរិយា យើងគួរកុំភ្លេចថា "ចូលស្រុកអ្នកមានក្អែកមួយ ត្រូវធ្វើឲ្យមានក្អែកមួយតាមគេ" ដូចជាយើងចូលទៅរកព្រះសង្ឃ ចូលទៅរកអ្នកមានទ្រព្យ អ្នកធំ ចូលគាល់ម្ចាស់ផែនដី ឬនាយ

ចៅហ្វាយ ចូលទៅក្នុងសមាគមបរជាតិ ឬក្នុងទីប្រជុំនឹងទីធ្វើបុណ្យ ពិធីតូចធំណាមួយ ត្រូវតែអនុលោមខ្លួនឲ្យសមគួរដល់បុគ្គល នឹងកាលៈទេសៈនោះៗ គួរថ្វាយបង្គំក៏ថ្វាយបង្គំ គួរគោរពក៏គោរព គួរលុតក្រាបក៏លុតក្រាប ឬគួរធ្វើសេចក្ដីគោរពយ៉ាងដទៃទៀត តាមសម័យនិយមដែលអ្នកប្រាជ្ញសរសើរ ក៏ធ្វើដែរ ៗ មនុស្សយើងមានរូបពណ៌សណ្ឋានផ្សេងៗគ្នា នឹងរើសយកតាមចិត្តប្រាថ្នាពុំបាន ស្រេចហើយតែកម្មដែលខ្លួនកសាងមក តាក់តែងឲ្យជាអ្នកមានរូបល្អខ្លះ អាក្រក់ខ្លះផ្សេងៗគ្នា ៗ អ្នកមានរូបល្អ រមែងជាទីនិយមចូលចិត្តរបស់ជនដែលបានឃើញ ប្រៀបដូចផ្កាឈើដែលមានពណ៌សណ្ឋានល្អ ៗ ឯអ្នកដែលមានរូបអាក្រក់ តែងមិនជាទីពិតពិលរមិលមើល នៃជនដែលបានឃើញ ដូចជាផ្កាឈើដែលមានពណ៌សណ្ឋានមិនល្អ ៗ តែកិរិយាដែលល្អ ប្រសើរជាងរូបល្អ ព្រោះមនុស្សមានកិរិយាល្អនោះ សូម្បីរូបមិនល្អក៏គង់ជាទីនាំឲ្យចាប់ចិត្ត ចាប់ភ្នែករបស់មនុស្សដទៃបាន ទាំងជាគ្រឿងណែនាំឲ្យគេយកចិត្តទុកដាក់នឹងខ្លួនផង គ្រាន់បើជាងមនុស្សមានរូបល្អដែលមានកិរិយាថោកទាប ៗ បើមានកិរិយាល្អ ហើយមានរូបល្អផងក៏រឹងរឹតតែជាទីស្រឡាញ់របស់ប្រជាជនថែមទៀត ៗ

មនុស្សមានកិរិយាថោកទាប សូម្បីជាអ្នកមានរូបល្អ ក៏តទល់នឹងមនុស្សមានរូបអាក្រក់ដែលមានកិរិយាល្អពុំបាន ៗ បើកិរិយាអាក្រក់

ហើយ រូបអាក្រក់ផង ក៏រឹងរឹតតែអភ័ព្វក្រៃលែងទៅទៀត មិនមាននរណាចូលចិត្តស្រឡាញ់រាប់អានឬស្រគសមាគមរួមជាមួយឡើយ ។ អញ្ជើញមើលចុះ ! ផ្កាឈើដែលមានពណ៌ខឹងទ្រង់ទ្រាយល្អ តែគ្មានក្លិនក្រអូប រមែងប៉ះនឹងផ្កាឈើដែលមានពណ៌សណ្ឋានអាក្រក់ តែមានក្លិនក្រអូបពុំបានទេ ; បើគ្មានក្លិនក្រអូប ថែមទាំងមានពណ៌ទ្រង់ទ្រាយអាក្រក់ទៀតផង ក៏រឹងរឹតតែជាទីមិនប្រាថ្នារបស់នរណាៗឡើយ ។

ផ្កាសោមាន់ ផ្កាពា មានពណ៌ល្អ
តែគ្មានក្លិន នោះក៏ គ្មានដំឡៃ
ដូចប្រុសស្រី រូបល្អ គួរពិស្ម័យ
តែកិរិយា វិស័យ សត្វតិរច្ឆាន ។
បើជាស្រី រូបល្អ គួរកិសរាង
តែឫកទើស ទ្រនង់ ពុំសមឋាន
ប្រុសបេះគិត មិនខ្វី ចង់រាប់អាន
ទាំងមិនបាន ងាកមើល ដោយស្នេហា ។
សូម្បីប្រុស ក៏ចុះ ក្បួនដូចគ្នា
ទើបឃើញថា ឫកពា ល្អថ្លៃថ្លា
នៅត្រង់ចិត្ត សុភាព បេះរាបសា
មិននៅត្រង់ រូបឋា ដែលល្អឡើយ ។

(មានត)

អំឡេះណា - សំមា្រណា

"រឿងព្រេងប្រទេសរូម៉ានី"

# លោក ផេង - ជីវ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង

(តមក)

លុះទ្រង់ទតព្រះនេត្រមើលសព្វគ្រប់ហើយ, ព្រះកដធីតារើសយក ដាវមួយដែលប្រេះតាបបន្តិច ប៉ុន្តែផ្លែ កង់វង់ដូចស្នែងក្របី ។ រួច ព្រះនាងប្រាប់យក្សថា: ស្អែកនេះនាងនឹងធ្វើដំណើរតទៅទៀត ។

ការជ្រើសរើសនៃព្រះកដធីតានេះ ធ្វើឲ្យនាងយក្ខិនីក្តៅក្រហាយ ពេក ព្រោះវាមិនអាចរកសេចក្តីពិតឃើញ ។ នាងយក្ខិនីប្រាប់កូនថា: ទោះបីអាការខាងក្រៅដូចប្រុសក៏ដោយ ក៏ព្រះអង្គម្ចាស់នេះឯងប្រាកដជា ស្រី ហើយជាស្រីឆ្លាតផុត ។ ដោយអស់សង្ឃឹមនឹងមធ្យោបាយដើម្បីដោះ ប្រស្នានេះ យក្សម្តាយនឹងកូននាំគ្នានៅឯក្រោលសេះ ហើយយកសេះ សុក្រាបកាថ្វាយព្រះកដធីតា។ ក៏លាយក្សធ្វើដំណើរចេញទៅ ។

សេះនិយាយថា: បពិត្រព្រះនាងម្ចាស់! តាំងពីដើមរហូតមកដល់ ថ្ងៃនេះ ទ្រង់តែងតែធ្វើតាមដំបូន្មានទូលព្រះបង្គំទាំងអស់ ហើយទ្រង់ ក៏បានឈ្នះមារសត្រូវគ្រប់កន្លែង ។ ឥឡូវនេះ, សូមព្រះនាងធ្វើតាម ដំបូន្មានទូលព្រះបង្គំម្តងទៀតចុះ ទ្រង់នឹងមិនមានសេចក្តីក្តៅក្រហាយព្រះ

ហ្ឫទ័យស្តាយក្រោយឡើយ ។ ឥឡូវនេះទូលព្រះបង្គំចាស់ណាស់ហើយ កំឡាំងមិនសូវមានប៉ុន្មាន ចុះប្រសិនបើទូលព្រះបង្គំទៅជាម៉េចៗទៅ... សុំព្រះនាងយកសេះសុរ្យាបកា ដែលត្រូវជាប្អូនទូលព្រះបង្គំជាជំនិះក្នុងដំណើរនេះចុះ ។ ទ្រង់ធ្លាប់មានព្រះហ្ឫទ័យជឿលើរូបទូលព្រះបង្គំយ៉ាងណា ក៏សូមទុកព្រះហ្ឫទ័យលើរូបសុរ្យាបកាយ៉ាងនោះ ។ ទ្រង់នឹងមិនស្តាយក្រោយទេ ។ សុរ្យាបកាក្មេងក៏ក្មេង រហ័សក៏រហ័សជាងទូលព្រះបង្គំ ហើយគេឲ្យដំបូន្មានដល់ទ្រង់ល្អជាងទូលព្រះបង្គំក្នុងពេលដែលមានការត្រូវធ្វើ ។

ព្រះរាជធីតាមានព្រះបន្ទូលតបថា ប្រាកដមែនហើយ បងមនោ-ម័យ! ខ្ញុំបានសម្រេចប្រយោជន៍គ្រប់ជង កាលណាខ្ញុំធ្វើតាមដំបូន្មានបងឯង ។ ខ្ញុំដឹងថា: បងមានចិត្តស្មោះត្រង់ចំពោះព្រះរាជបិតាខ្ញុំណាស់, បើដូច្នេះ ខ្ញុំត្រូវតែស្តាប់ពាក្យរបស់បងទៀត ។ ប៉ុន្តែខ្ញុំចង់ដឹងឲ្យជាក់ច្បាស់ តើប្អូនរបស់បងមានសេចក្តីទុកចិត្តលើរូបខ្ញុំដូចខ្លួនរបស់បងឬទេ? ត្រូវឲ្យគេសំដែងសេចក្តីស្នេហាឲ្យឃើញចំពោះខ្លួនខ្ញុំសិន ។

សុរ្យាបកាក្រាបបង្គំទូលថា: សូមទ្រង់ទុកព្រះរាជហ្ឫទ័យលើរូបទូលព្រះបង្គំចុះ, ទូលព្រះបង្គំត្រេកអរជាពន់ពេក ដោយបានព្រះអង្គម្ចាស់ហារហានដូចជាទ្រង់គង់លើខ្នង, ហើយទូលព្រះបង្គំនឹងខំយកចិត្តទុកដាក់ធ្វើការថ្វាយទ្រង់តាមចំណេះដែលអាចធ្វើបាន ដូចជាបងរបស់

ទូលព្រះបង្គំដែរ ។ ទូលព្រះបង្គំមានបំណងចង់រំដោះសេចក្ដីព្រួយនឹងគ្រោះថ្នាក់ដែលទ្រង់ត្រូវជួបប្រទះ អំពីបងទូលព្រះបង្គំផង ព្រោះគាត់ចាស់ហើយៗ ទ្រង់មុខជាប្រាប់ហើយថា យើងទៀងតែត្រូវផ្ដាញ់ខ្លួនសេចក្ដីលំបាកនឹងមរណភ័យក្នុងផ្លូវជាមិនខាន ។

ក្សណនោះ ព្រះរាជធីតាទ្រង់ព្រះកន្សែង ដោយការអាឡោះអាល័យចំពោះព្រះរាជអស្សពាហន៍ចាស់ ហើយទ្រង់ក៏ឡើងគង់លើខ្នងសុព្រាបកាអាជានេយ្យបរទៅ ។

ព្រះនាងគង់លើព្រះរាជទីនាំងសុព្រាបកាបរទៅមិនបានជាយូរប៉ុន្មាន, ទ្រង់ប្រទះឃើញកម្រងសក់មាសមួយជ្រុះនៅដី ។ នាងបញ្ឈប់សេះ ហើយសួរថា តើត្រូវរើសយកកម្រងសក់នេះទុក ឬដូចម្ដេច? ។ សេះក្រាបបង្គំទូលថា: បើទ្រង់រើស ទ្រង់នឹងមានសេចក្ដីស្ដាយក្រោយ, បើទ្រង់មិនរើសយក ទ្រង់ក៏មានសេចក្ដីស្ដាយក្រោយដែរ ; បើដូច្នោះត្រូវរើសយកទុកល្អជាជាង ។ នាងពៅរើសកម្រងសក់ទុកក្នុងព្រះពស្ដ្រ ហើយធ្វើដំណើរតទៅទៀត ។

ព្រះនាងធ្លងកាត់គិរីបពិត ធ្លងជ្រោះ ធ្លងព្រៃញាតស្បាតស៊ុបទ្រុប, ចំការពោសពេញដោយបុប្ផជាតិផ្សេងៗ ដែលព្រះនាងមិនដែលប្រទះធ្លង, ជ្រោះមានទឹកថ្លាត្រជាក់; ក្នុងទីបំផុត ព្រះនាងក៏បានទៅដល់ព្រះរាជវាំងនៃព្រះចៅរាជាធិរាជដ៏ទ្រង់នូវរិទ្ធានុភាពអស្ចារ្យ ។

ថ្លែងអំពីព្រះរាជបុត្រទាំងឡាយ នៃស្ដេចប្រទេសរាជដទៃដែលនៅក្នុងវាំងនោះ នាំគ្នាមកទទួលនូវអាគន្តុករាជបុត្រ ហើយមិនអាចងាកមុខចេញពីព្រះភក្ត្រនៃនាងពៅ ព្រោះព្រះនាងមានស្នេហ៍នៅត្រង់ព្រះរាជា និងព្រះភក្ត្រ ។

ព្រឹកឡើង ព្រះនាងស្ដេចទៅថ្វាយបង្គំគាល់សម្ដេចព្រះចៅរាជាធិរាជ ហើយទូលថ្វាយដំណឹងដល់ព្រះអង្គ អំពីហេតុដែលនាំឲ្យព្រះនាងយាងមកក្នុងទីនេះ ។ ព្រះចៅរាជាធិរាជទ្រង់មានព្រះហឫទ័យត្រេកអរជាពន់ពេក ដោយឃើញអ្នកហាវហានមានមុខស្រស់បស់មកដល់ ទ្រង់សព្វព្រះហឫទ័យនឹងចម្លើយរបស់ព្រះនាងដែលប្រកបដោយសេចក្ដីគោរព និងពេញដោយការស្លូតបូតរាបសា, ទ្រង់ពេញព្រះហឫទ័យនឹងព្រះរាជធីតាពេក ក៏ទ្រង់តាំងឲ្យព្រះនាងនៅធ្វើការថ្វាល់ព្រះអង្គ ។ ព្រះនាងមាណវីរាជធីតា មិនបានមានការទាក់ទងរវាងព្រះរាជបុត្រជាគូកនទាំងឡាយឯទៀត ដែលច្រើនតែជាអ្នកលោភលន់ ជាអ្នកកំជិលហើយនឹងជាអ្នកមានប្រាជ្ញាមិនពេញលេញទេ ។ ហេតុដូច្នេះ ព្រះរាជបុត្រទាំងនេះមានចិត្តឈ្នានីសប្រច័ណ្ឌអាឃាតចំពោះព្រះអង្គម្ចាស់ក្សត្រី ព្រោះព្រះចៅមានព្រះហឫទ័យស្រឡាញ់ប្រោសប្រណីព្រះនាងជាងគេ ។

មានថ្ងៃមួយ នាងពៅទ្រង់ដាំស្លដោយព្រះអង្គឯងម្ដង, ហើយវេលាដែលព្រះនាងកំពុងសោយព្រះក្រយាស្ងោយ ស្រាប់តែព្រះរាជបុត្រ

ពីរព្រះអង្គយាងមកឃើញ ។ ព្រះរាជបុត្រទាំងពីរនេះក៏ចូលសោយជាមួយនឹងព្រះនាង ។ ព្រះក្រយាស្ងោយនុ៎ះត្រូវព្រះឱស្ឋពេក ទាល់តែព្រះអង្គម្ចាស់ទាំងពីរសោយលិទ្ធព្រះហស្ត ហើយទ្រង់សរសើរព្រះនាងអំពីការចេះដណ្តាំស្លថា : ខ្ញុំមិនដែលសោយក្រយាស្ងោយណាមានឱជារសជាងនេះសោះ ។

កូនស្តេចទាំងពីរនិយាយសរសើរប្រាប់មិត្តភក្តិទាំងពួងថា: បានសោយអាហារជាមួយនឹងព្រះអង្គម្ចាស់អាគន្តុក:, ថាអាហារនុ៎ះមានឱជា-រសលើសលុបជាងព្រះស្ងោយនៃព្រះចៅរាជាធិរាជទៅទៀត, ថាអាហារនោះ ជាអាហារដែលនាងដណ្តាំស្លដោយខ្លួនឯង ។ កាលនោះ អស់ទាំងព្រះរាជបុត្រនាំគ្នាទៅអង្វរសូមឲ្យព្រះនាងដណ្តាំស្លម្តងទៀត ។ ជួនជាទេសកាលអ្វីថ្ងៃនោះនាយពិសេសស្រវឹងស្រាទាំងអស់គ្នា ហើយនៅក្នុងដើងក្រោករកក្រើងគ្មាន ; ព្រះនាងក៏ព្រមទទួលធ្វើតាមពាក្យអង្វរនៃព្រះរាជបុត្រទាំងឡាយ ។ សម្លដែលព្រះនាងពៅធ្វើមានឱជារសពន់ពេក ។ កាលនោះគេលើកព្រះក្រយាស្ងោយទៅថ្វាយព្រះចៅរាជាធិរាជ, ព្រះអង្គទ្រង់សោយមិនចង់ឈប់ ។ ទ្រង់ក៏ហៅនាយពិសេសមកហើយមានព្រះរាជឱង្ការបង្គាប់ថា: ទៅថ្ងៃមុខទៀតត្រូវធ្វើតែបែបដូច្នេះ ។ ប៉ុន្តែនាយពិសេសរាយសេចក្តីក្រាបបង្គំទូលថ្វាយ អំពីអ្នកដែលធ្វើព្រះក្រយាស្ងោយនេះ ។ ព្រះចៅរាជាធិរាជស្តាប់តែទ្រង់នៅស្ងៀម ហើយទ្រង់ព្រះតម្រិះតែក្នុងព្រះរាជហឫទ័យ ។

លុះកាលកន្លងមកមិនយូរប៉ុន្មាន ព្រះរាជបុត្រនៃព្រះរាជាដទៃមកក្រាបបង្គំថ្លែងសេចក្តីថ្វាយព្រះចៅរាជាធិរាជថា: មានមួយថ្ងៃ ពួកទូលព្រះបង្គំបានទទួលទានអាហារជាមួយនឹងអាគន្តុករាជបុត្រៗ បាននិយាយអួតថា: ខ្លួនស្គាល់ទីលំនៅនៃនាង "អ៊ីឡេណា - សិម្យ៉ាណា" ដែលមានកម្រងសក់មាស មាត់ទិព្យ បេះផ្លែឈើឲ្យលូតលាស់សន្ទឹក ឲ្យមានផ្កាផ្លែ, ហើយថែមទាំងថាខ្លួនមានកម្រងសក់មាសមួយដុំផង ។

ព្រះបាទរាជាធិរាជលុះទ្រង់ព្រះសណ្តាប់ដូច្នោះ ទ្រង់ក៏ឲ្យគេហៅព្រះអង្គម្ចាស់ហាវហានមកភ្លាម ហើយមានព្រះរាជឧង្ការបន្ទោសថា: ឯងដឹងកន្លែងនៃនាង "អ៊ីឡេណា - សិម្យ៉ាណា" ហើយឯងគ្មាននិយាយប្រាប់យើងសោះ យើងថាមុកចិត្តលើឯង ហើយស្រឡាញ់ឯងជាងគេ ។

ព្រះចៅទ្រង់បង្គាប់ឲ្យព្រះនាងយកកម្រងសក់មាសមក ហើយមានព្រះបន្ទូលបន្ថែមថា: បទបញ្ជានៃព្រះរាជាធិរាជ ថាត្រូវឯងទៅនាំនាងអ៊ីឡេណា - សិម្យ៉ាណាឲ្យបានមក បើឯងមិនចង់ឲ្យក្បាលឯងរមៀលមកដី ។

ព្រះនាងកំសត់រកនិយាយក្រាបទូលអ្វីមិនកើត ព្រោះព្រះចៅចេះតែមានព្រះឧង្ការស្អាក់អស់ ។ ទាល់ចំណោះ នាងពៅយករឿងនេះទៅនិយាយប្រាប់សេះៗក្រាបបង្គំទូលថា: បពិត្រព្រះនាងជាម្ចាស់! សូមទ្រង់កុំភ័យបារម្ភ ។ យប់មិញបងទូលព្រះបង្គំបាននិយាយប្រាប់ថា:

នាងកម្រែងសក់មាស ឥឡូវយក្សចាប់យកទៅហើយ ។ តែនាងមិនទាន់ព្រមយកយក្សធ្វើជាប្ដីនៅឡើយ មុនដែលយក្សទៅរកហ្វូងមេសេះមកប្រគល់ឲ្យនាង ។ ហើយយក្សកំពុងតែក្ដៅក្រហាយក្នុងចិត្ត ព្រោះមិនដឹងនឹងទៅរកហ្វូងមេសេះឯណាមក ដើម្បីនឹងបំពេញចិត្តនាង ។ ឥឡូវនេះនាងអ៊ីឡេណា សិម្យ៉ាណានៅក្នុងកោះកណ្ដាលសមុទ្រ ។ សូមព្រះនាងយាងទៅទូលព្រះចៅវិញថា ត្រូវការសំពៅម្ដៃហើយផ្ទុកសុទ្ធតែទំនិញយ៉ាងល្អៗ ។

ព្រះរាជធីតា ក៏ស្ដេចទ្រង់យាងទៅក្រាបទូលព្រះចៅថា: បពិត្រព្រះអង្គដ៏ទ្រង់នូវបុណ្យបារមី! សេចក្ដីបង្គាប់របស់ទ្រង់ទាំងប៉ុន្មាន ទូលព្រះបង្គំនឹងបំពេញថ្វាយ ប៉ុន្តែសូមទ្រង់ប្រទានសំពៅម្ដៃ នឹងមាសប្រាក់យ៉ាងច្រើន ព្រមទាំងទំនិញទំនិញដាក់យកទៅផង ។

ព្រះចៅឆ្លើយថា: តាមតែឯងធ្វើដូចម្ដេចក៏ដោយ ឲ្យតែនាំនាងអ៊ីឡេណា - សិម្យ៉ាណាបានមកឲ្យយើង ។

មិនយូរប៉ុន្មានសំពៅក៏ធ្វើបានក្លាម ហើយផ្ទុកសុទ្ធតែទំនិញយ៉ាងមានដំឡៃ ។ ព្រះរាជធីតានឹងសុរ្យាបកាឡើងគង់លើសំពៅមួយដែលល្អជាងគេ ហើយនាំគ្នាចេញទៅ ។ គ្មានខ្យល់គ្មានរលកអ្វីអាចបញ្ឈប់ដំណើរនៃព្រះនាងបានទេ ហើយខាងក្រោយដែលបានបើកសំពៅអស់ច្រើនសប្ដាហ:ទើបបានដល់កោះយក្ស ។ ព្រះរាជធីតាយកស្បែកជើង

មួយគូ ប៉ាក់ខ្សែសយមាសលំអដោយត្បូងពេជ្រ ទ្រង់កាន់ចេញយាងទៅតាមឆ្នេរសមុទ្រជាមួយនឹងសុរ្យាបភា ៗ មួយស្របក់ ព្រះនាងទតព្រះនេត្រឃើញប្រាសាទយក្សនៅអណ្តែតលើព្រះធរណីវិលបាន គឺប្រាសាទនោះបែរមុខទៅរកតែព្រះអាទិត្យ ដូចជាមេដែកតម្រង់ទៅតែទិសឧត្តរ ហើយព្រះនាងទ្រង់យាងចំពោះប្រាសាទនោះ ៗ កំពុងតែស្តេចទៅ ព្រះនាងបានជួបនឹងបរិចារិកាបីនាក់របស់យក្ស ដែលឲ្យនៅចាំថែរក្សានាង អ៊ីឡេណា - សិម្យ៉ាណា ៗ ស្រីទាំងបីលុះបានឃើញស្បែកជើងល្អអស្ចារ្យ ក៏សំឡឹងមើលមិនដាក់ភ្នែក ៗ ព្រះរាជធីតាតាំងខ្លួនជាឈ្មួញសំពៅវង្វេងផ្លូវក្នុងសមុទ្រ ៗ

នាងស្រីបំរើ ៣ នាក់ទៅនិយាយប្រាប់ម្ចាស់ក្សត្រីអំពីវត្ថុដែលវាបានឃើញ ៗ ចំណែកនាងអ៊ីឡេណា - សិម្យ៉ាណា គ្រាន់តែក្រឡេកឃើញឈ្មួញពីព្រះសីហបញ្ជរ ស្រាប់តែរំភើបក្នុងដើមទ្រូង មិនដឹងជាមានហេតុអ្វី ហើយនាងហាក់ដូចជាសប្បាយចិត្ត ដោយគិតឃើញថាប្រហែលខ្លួននាងបានរួចចេញពីកណ្តាប់ដៃយក្សជាមិនខាន ព្រោះយក្សមិននៅ ដោយសារនាងបានបញ្ជូនវាឲ្យទៅរកពួកមេសេះមកឲ្យនាង ៗ

(មានត)

# រឿងសាមកុក

កណ្ឌទី ៩

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

ប៊ូធូបានឮក៏សើចហើយតបថា "លីប៉ោនោះជាមនុស្សមិនបេះគិត កាលណាឡើយនឹងយកទាហានទៅបង្កប់នៅទីនោះ, យើងដឹងថា ឥឡូវនេះលីប៉ោឲ្យលីហាងនឹងស៊ីឡាន់ផ្ដុំទាហានទៅរក្សាស្រុកគុនជីវ ខ្លួនលីប៉ោឯងទទួលទ័ពនៅរក្សាស្រុកប៉ាក់អៀង, ដូច្នេះយើងត្រូវបញ្ជូនហោយ៉ិនឲ្យលើកទាហានជាច្រើនទៅឡោមព័ទ្ធស្រុកគុនជីវជាមុន" ថាហើយក៏លើកទាហានទន្ទ្រានទៅតាមច្រកភ្នំថៃសាន់ ។

តាន់គុងដឹងដូច្នោះក៏និយាយនឹងលីប៉ោថា ប៊ូទ្រុសតលើកទាហានតមកដោយកំឡាំងក្រោធខឹង ខ្ញុំដឹងថាទាហានទាំងនោះមុខជាហត់នឿយ

ខ្លាំងណាស់ សុំឲ្យលោកបង្ខំលើកទាហានខាងយើងចេញទៅទទួលតទល់ជាឆាប់ យើងគង់នឹងបានចំណាប់ឈ្មោះបូឆូជាប្រាកដ, បើបង្អង់ឲ្យយូរទាហានបាត់នឿយហត់ទៅវិញ យើងនឹងផ្ចាញ់បានដោយកម្រណាស់ ៗ លីប៉ោតបថា មុនយើងនឹងតាំងខ្លួន យើងមានត្រឹមតែខ្លួនមួយហើយនឹងសេះប៉ុណ្ណោះ លុះបានធ្វើការសង្គ្រាមតាមលំដាប់រៀងមក ទាល់តែបានសេនាទាហានដល់ប៉ុណ្ណេះហើយ មិនត្រូវគិតកោតញញើតបូឆូនោះសោះឡើយ ទោះបីបូឆូនឹងមកតាំងបន្ទាយឲ្យមាំមួនយ៉ាងណា យើងក៏ត្រូវតែពុះពារទំលាយវាយយកឲ្យបាន ៗ

ខណៈនោះ បូឆូបានលើកទ័ពមកដល់ស្រុកប៉ាក់អៀង ហើយឲ្យតាំងបន្ទាយកាយសេនាទាហានជាមាំមួនបានស្រេចទាំងអស់ ៗ លុះព្រឹកឡើងពួកទាហានចេញទៅដំរៀបនៅមុខបន្ទាយ បូឆូជានាយជិះសេះចេញទៅឈរនៅមុខទាហាន បានក្រឡេកឃើញលីប៉ោនឹងទាហានឯក ៨ នាយ ឈរអមទាំងឆ្វេងស្ដាំគឺឈ្មោះតៀវលៀវ ១, ចុងប៉ា ១, ឡាន់ប៉េង ១, សោស៊ុន ១ សេងលៀម ១, ប៊ុយសុក ១, សុងហៀន ១, ហោសេង ១ នឹងទាហានឡើងជាច្រើនហ៊ោកញ្ជ្រៀវគឹកកងចេញមក ៗ បូឆូយករំពាត់សេះចង្អុលមុខលីប៉ោហើយថា ខ្លួនហើយនឹងយើងនឹងបានមានទោសទាស់គ្រោះអ្វីក៏ទេ ហេតុម្ដេចខ្លួនក៏លើកទាហានមកវាយយកស្រុករបស់យើងដូច្នេះ ៗ

លីប៉ោឆ្លើយថា "ស្រុកទាំងអម្បាលនេះ ជារបស់ព្រះមហាក្សត្រិយ៍ ក៏ទុកដូចជារបស់មនុស្សប្រុសស្រីទាំងពួង ដែលនៅលើផែនដី បើអ្នកឯណាមានបុណ្យរិទ្ធីខ្លាំងពូកែជាងគេ ត្រូវតែគ្រប់គ្រងស្រុកនីមួយៗបានដូចគ្នា, ហេតុម្តេចអ្នកមកថា ស្រុកនេះជារបស់អ្នក អ្នកគ្មានសេចក្តីអៀនខ្មាសទេឬ?" ថាហើយក៏ប្រើចុងប៉ាឲ្យចេញទៅចាប់ចូឆូ ៗ ចូឆូឲ្យឆាក់ជិនចេញមកតយុទ្ធគ្នានឹងចុងប៉ាបាន ៣០ ស្នៀត ៗ ហែហូទុនបរសេះចេញទៅជួយឆាក់ជិន តៀវលៀវក៏ចេញមកតយុទ្ធនឹងហែហូទុន ៗ ទាហាន ៤ នាយប្រយុទ្ធគ្នា ជាអង់អាចមិនបានចាញ់ឈ្នះ, លីប៉ោឃើញដូច្នោះខឹងណាស់ បររសេះកាំទួនទៅតនឹងហែហូទុន ឆាក់ជិន, ឯហែហូទុននឹងឆាក់ជិនតស៊ូនឹងលីប៉ោមិនបានក៏ញាក់សេះថយរត់, លីប៉ោស្ទុះដេញប្រយុទ្ធពីក្រោយ ទាហានចូឆូបែកខ្ចាត់ខ្ចាយអស់ទៅ លីប៉ោញាក់សេះត្រឡប់មកវិញ ៗ ចូឆូសៀបប្រៀបនឹងលីប៉ោក៏ថយទ័ពត្រឡប់ចូលបន្ទាយ ហើយប្រឹក្សានឹងសេនាទាហានទាំងពួងថា លីប៉ោកំឡាំងខ្លាំងពូកែណាស់ នឹងរកអ្នកឯណាតស៊ូមិនបាន ៗ

អ៊ូគីមឆ្លើយថា ខ្ញុំបាទឡើងទៅលើភ្នំឃើញបន្ទាយលីប៉ោទិសខាងលិចមានទាហានស្តើងណាស់, ដែលលីប៉ោច្បាំងឈ្នះចូលទៅគ្រានេះ មុខជានឹងមានចិត្តកំរើបមើលងាយ, ទាហានលីប៉ោគង់នឹងប្រមាទមិនបានរក្សាបន្ទាយឲ្យមាំមួនទេ; វេលាយប់នេះ សុំឲ្យលោកលើកទាហានចូល

បូនយកបន្ទាយលីប៉ោ គង់នឹងបានដោយងាយ ៗ ចូឆូក៏យល់ព្រមផង ទើបចាត់ចោហង ១ លីតៀន ១ លីយ៉យ ១ អ៊ុគីម ១ តៀនអ៊ុយ ១ នឹងទាហានឡេវប្រហែល ២ ម៉ឺនត្រៀមទុកជាស្រេច ៗ

ឯលីប៉ោកាលត្រឡប់ទៅក្នុងបន្ទាយ បង្គាប់ឲ្យរៀបចំលៀងសេនាទាហាននឹងឲ្យបំណាច់រង្វាន់ទាំងពួងតាមសមគួរ ៗ គាត់ក៏និយាយនឹងលីប៉ោថា ដែលចូឆូបែកទ័ពទៅនោះ មុខជានឹងមានសេចក្ដីគិតត្រឡប់មកធ្វើការសងសឹកវិញជាប្រាកដ, ខ្ញុំឃើញថាបន្ទាយទិសខាងលិចមានទាហាន នៅស្ដើងស្ដួចណាស់ សុំឲ្យប្រមូលទាហានទៅបំពេញឲ្យមាំមួនឡើងវិញ ៗ លីប៉ោតបថា ចូឆូបែកទ័ពទៅពីព្រោះចាញ់ប្រៀបយើង ប្រហែលមិនគិតមកបូនបន្ទាយយើងវិញទេ ៗ គាត់ក៏ថាលោកកុំអាលទុកចិត្ត ដ្បិតចូឆូជាមនុស្សមានសតិបញ្ញាឆ្លៀវឆ្លាតក្នុងការសង្គ្រាមណាស់, ខ្ញុំឃើញថាមុខជានឹងលើកទ័ពមកបូនបន្ទាយជាប្រាកដ ៗ លីប៉ោឃើញត្រូវផង ទើបចាត់ឲ្យកោស៊ុន ១ ង៉ុយសុក ១ ហោសេង ១ នាំយកទាហានជាច្រើនទៅរក្សាបន្ទាយទិសខាងលិចជាយ៉ាងមាំមួន ៗ

លុះដល់ពេលកណ្ដាលយប់ប្រហែលយាមពីរបាយ ចូឆូក៏លើកទាហានដែលត្រៀមទុកនោះទៅព័ទ្ធផ្លូវពីទិសខាងត្បូង ចូលទៅជិតដល់បន្ទាយហើយក៏ឲ្យរាយព័ទ្ធជុំវិញ ហើយហោរេតស្រែកទៅលុកកាប់យកបន្ទាយនោះបាន ៗ ទាហានលីប៉ោដែលនៅក្នុងបន្ទាយ ក៏បែកធ្លាយ

រត់ចេញទៅ; ឯង៉ុយស៊ុក ១ ហោសេង ១ កោស៊ិន ១ ដែលលីប៉ោឲ្យនាំទាហានទៅរក្សាបន្ទាយនោះ បានលើកទៅជិតបន្ទាយក្នុងពេលនោះ លុះឃើញទាហានចូចូប៊ុនយកបន្ទាយបាន ក៏នឹកភ័យខ្លាចលីប៉ោនឹងយកទោសទុស ទើបរំបែប ព្រុះពុះពារបង្ក្រាំងយកបន្ទាយបានមកវិញ ។ ចូចូឃើញដូច្នោះ ក៏លើកទាហានគ្នាខាងក្រៅ; សន្ធឹកទាហានទាំងសងខាងដែលប្រឡូកច្បាំងគ្នាក្នុងពេលយប់នោះ ហាក់បីដូចខ្យល់ព្យុះសង្ឃ្រាក កក្រើកទាំងផែនពសុធាគឹកកងរំពងទាល់តែភ្ញាក់ស្មាង ។

លីប៉ោបានដឹង ក៏តាំងលើកទាហានស្រុតត្រមង់ទៅបន្ទាយខាងត្បូងទៀត ។ បំរើសេះនាំសេចក្តីនោះទៅប្រាប់ចូចូថា បានឃើញលីប៉ោលើកទាហានមកជិតនឹងដល់ហើយ ។ ចូចូបានឮជាក់ក៏តក់ស្លុតក្នុងចិត្ត គិតនឹងលើកទាហានត្រឡប់បែរមុខទៅក្រោយរត់បណ្ដោយទៅ ។ កោស៊ិន ង៉ុយស៊ុក ហោសេង ឃើញដូច្នោះក៏លើកទាហានបង្រ្ទះតាមពីក្រោយដូចគេខ្ទប់ប្រសព្វគ្នានឹងទ័ពលីប៉ោពីមុន តាំងតែគ្រលុកប្រកាប់គ្នាទៅវិញទៅមក ។ ចូចូប្រើអ៊ីគីមនឹងឆៅក់ជិនចេញតនឹងទ័ពលីប៉ោដោយអង់អាច, តែអ៊ីគីមនឹងឆៅក់ជិនកម្លាំងតិច តស៊ូនឹងលីប៉ោពុំបាន ក៏ញាក់សេះស្ទុះរត់ត្រឡប់ក្រោយនាំចូចូរគេចបណ្ដោយទៅទិសឯជើង ។ លីប៉ោស្ទុះឡើងតាមចាក់កាប់សម្លាប់ទាហានចូចូស្លាប់គរលើគ្នា; ឯចូចូ អ៊ីគីម នឹងឆៅក់ជិន ក៏លើកទាហានរត់ទៅដល់ជើងភ្នំ ១ ទទួលជួបនឹង

តៀវលៀវ ហោប៉ា លើកទ័ព ២ កង មកវង់ស្ទាក់ពីមុខ; ចូឆូក៏ឲ្យហោហង់ នឹងលីយ៉យចេញតយុទ្ធគ្នា នឹងតៀវលៀវ ហោប៉ាយ៉ាងមាំមួន; ហោហង់ លីយ៉យតស៊ូមិនឈ្នះក៏ញាក់សេះប្រាសថយក្រោយ នាំចូឆូនឹងទាហាន រត់រិលបណ្ដោយទៅទិសឯត្បូង ទទួលប្រទះនឹងឡាន់ប៉េង ហោសេង សេងលៀម សុងហៀនទាំង ៤ នាក់ លើកទាហានជា ២ កងវង់ស្ទាក់ ជាប់; ចូឆូក៏បង្ខំកងទ័ពបុលប្រកាប់គ្នាជាច្រឡំបល់ ចូឆូយល់ថាកម្លាំង ថយអន់ណាស់, ទ័ពលីប៉ោព័ទ្ធស្ទាក់ជុំវិញចេញពុំបាន ចូឆូក៏ខំស្ទុះ បំពានរួចជាមួយនឹងទាហាន ៥ នាក់ លុះដល់ទៅជើងភ្នំមួយ ឮសូរ សំឡេងផាវលើភ្នំ ចូឆូក្រឡេកមើលទៅឃើញទាហានបាញ់ធ្នូតម្រង់មក ព្រួញហាក់ដូចគេបាចសាច, ចូឆូរឹតតែខ្លាចញញើត ក៏ញាក់សេះត្រឡប់ មកវិញ ពួកទាហានលីប៉ោតាមដេញឡោមព័ទ្ធជុំវិញចូឆូ ៗ ភ័យណាស់ ក៏ស្រែកថា នរណាមានកំឡាំង ចូរជួយប្រឹងយកអាយុយើងផង ៗ តៀនអ៊ុយឮហើយក៏ថា: "លោកកុំភ័យបារម្ភសុំខ្ញុំជួយ" ហើយក៏លោត ចុះពីលើសេះ យកទួនផ្ទៃ ២ ក្បៀតកូនក្លៀកហើយកន្ទ្រាក់យកលំពែង ពួយកាន់ទុកប្រហែល ១៥ ផ្ទៃ ទើបបង្គាប់ទាហាន ៥ នាក់ដែលមកជា មួយផងនោះថា "បើឃើញពួកសត្រូវមកជិតប្រហែល ៥ ព្យាម ចូរ ប្រាប់យើង" ហើយក៏នាំមុខសេះចូឆូបាញ់ធ្នូតទៅវិញ ៗ. ទាហាន លីប៉ោលើកតាមមកពីក្រោយប្រហែល ២០ នាក់ ពួកចូឆូក៏ស្រែកប្រាប់

គៀនអ៊ុយថា សត្រូវតាមមកជិតប្រហែល ៥ ព្យាមហើយ ។ គៀនអ៊ុយបានឮក៏បង្អង់ហើយយកព្រួញបាញ់ ទៅត្រូវទាហានសត្រូវធ្លាក់ពីលើសេះស្លាប់ ។ គៀនអ៊ុយក៏ចេះតែបាញ់ទាល់តែអស់ព្រួញពីដៃត្រូវសត្រូវគប់ព្រួញ, ទាហានដែលលើកតាមពីក្រោយនៅសល់ប្រហែល ៤ - ៥ នាក់ក៏រត់ត្រឡប់ថយក្រោយទៅវិញ ។ គៀនអ៊ុយក៏គៀនសេះនាំប្អូនទឹងរត់ចូលទៅក្នុងបន្ទាយ លុះទៅដល់កណ្ដាលផ្លូវជួនពេលថ្ងៃល្ងាច បានឮសំឡេងទាហានស្រុកហៅតាមមកទៀតជាច្រើន ។ ប្អូនក្រឡេកទៅក្រោយឃើញលីប៉ោបរសេះស្ទុះមកមុខទាហាន ក៏មានសេចក្ដីភិតភ័យខ្លាំងណាស់ ។ ឯទាហានដែលតាមមក ៥ នាក់នោះ នឿយហត់អស់កំឡាំងទាំងមនុស្សទាំងសេះ ក៏នាំគ្នាស្ទុះរត់ព្រាត់បែកគ្នាអស់ទៅ នៅតែគៀនអ៊ុយនឹងប្អូន ២ នាក់ ទទួលក្រឡេកទៅឃើញហៃហ្វុទនលើកទាហានចេញមកពីម្ខាងជួបនឹងប្អូន ។ ហៃហ្វុទនក៏ចូលច្បាំងកំពុងតនឹងលីប៉ោទាល់តែព្រលប់ ; យប់នោះ មានបណ្ដាលព្យុះខ្យល់វិលធ្លាក់ភ្លៀងធំ លីប៉ោលើកទាហានត្រឡប់ទៅវិញ ។

ឯប្អូននាំហៃហ្វុទននឹងគៀនអ៊ុយចូលបន្ទាយ ហើយយកប្រាក់មាសឲ្យជាបំណាច់រង្វាន់គៀនអ៊ុយជាច្រើន ។ លុះព្រឹកឡើង តាន់កុងនិយាយនឹងលីប៉ោថា ហៅហ្វាយស្រុកប៉ាក់អៀងនោះរត់បាត់ទៅហើយ, ក្នុងស្រុកនោះមានសេដ្ឋីម្នាក់ឈ្មោះគៀនស៊ុំជាមនុស្សស្លូតត្រង់ នឹងជាទីរាប់អាន

ដល់បណ្ដាអ្នកស្រុកទាំងពួង, បើតៀនស៊ុនឹងនិយាយការអ្វី អ្នកស្រុកក៏ជឿស្ដាប់គ្រប់គ្នាទាំងអស់ សុំឲ្យលោកហៅយកខ្លួនតៀនស៊ុមកនិយាយ ហើយឲ្យមានសំបុត្រទៅដល់បូឆូថា លោកមានជ័យជំនះដោយយកបានស្រុកប៉ាក់អៀង ឥឡូវនេះកោស៊ុននៅរក្សាស្រុកនោះ ឯខ្លួនលោកនឹងលើកទ័ពទៅវាយយកស្រុកលីយ៉ុងវិញ ឲ្យបូឆូលើកទាហានទៅប្លន់យកស្រុកប៉ាក់អៀងចុះ លោកត្រូវឲ្យតៀនស៊ុទៅឃុំរក្សាបណ្ដាអ្នកស្រុកទុកជាកងទ័ពសន្ទប់ ឯខ្លួនយើងត្រូវលបលើកទាហានចូលទៅនៅក្នុងស្រុកប៉ាក់អៀង ហើយយកឧសទៅគរទុកនៅមុខទ្វារទាំង ៤ ទិសឲ្យស្រេច បើឃើញបូឆូលើកទ័ពមកដល់ យើងត្រូវដុតភ្លើងឲ្យឆេះឡើងកណ្ដាលស្រុក ដុតទាំងគំនរឧសទាំង ៤ ទិសឲ្យឆេះស្មើគ្នា ទោះបីបូឆូនឹងមានសេចក្ដីគិតយ៉ាងណា ក៏ឃើញថាគង់នឹងមិនរួចពីដៃយើង ។ លីប៉ោបានស្ដាប់ក៏ចាប់ចិត្តគិតឃើញត្រូវក៏ហៅតៀនស៊ុចេញមក ហើយនិយាយល្បងលួងលោមយកចិត្តតាមគំនិតគាន់ក្នុងពន្យល់នោះ ។ តៀនស៊ុក៏ព្រមធ្វើតាម, លីប៉ោនឹងតៀនស៊ុក៏នាំគ្នាត្រឡប់ចូលទៅក្នុងស្រុក ហើយធ្វើសំបុត្រចាត់អ្នកបំរើស្និទ្ធយកទៅឲ្យបូឆូក្នុងបន្ទាយ ។

បូឆូទទួលយកសំបុត្រទៅឃើញសេចក្ដីថា ខ្ញុំបាទឈ្មោះតៀនស៊ុជំរាបមកលោកបូឆូបានជ្រាប ដែលលីប៉ោជាមនុស្សអាក្រក់លើកទាហានទៅវាយស្រុកប៉ាក់អៀងធ្វើអន្ដរាយដល់បណ្ដាកស្ត្រ ក្នុងស្រុកឲ្យបាន

សេចក្ដីទុកក្ដៅក្រហាយនោះ ឥឡូវនេះលីប៉ោមានសេចក្ដីកំរើបលើក
តាហានទៅកយស្រុកលីយ៉ុង ហើយឲ្យគោស៊ុន ហោសេងនៅគ្រប់គ្រង
ក្រោស្រុកនុ៎ះ សូមឲ្យលោកលើកតាហានចូលទៅប្ដូរយកស្រុកនេះជា
ប្រញាប់ចុះ ខ្ញុំបាទនឹងដោតទង់សរទុកជាសំគាល់ ហើយនឹងលើកពួក
អ្នកស្រុកចូលគ្រលុកជាទ័ពផ្ទប់ពីម្ខាង ឃើញនឹងបានស្រុកប៉ាក់អៀង
ដោយងាយ ៗ

ចូឆូបានឃើញសេចក្ដីសំបុត្រដូច្នោះ ក៏មានសេចក្ដីស្មោះសរអរមិន
មានសន្ទិះសង្ស័យ ទើបយកសំពត់មានដំឡៃឲ្យជាបំណាច់ផ្ញើទៅអ្នកកាន់
សំបុត្រ ហើយឲ្យទៅប្រាប់គៀនស៊ីវិញថាយើងនឹងធ្វើតាម ៗ អ្នកបំរើ
ក៏លាត្រឡប់វិលទៅវិញ ៗ ចូឆូនិយាយថា "យើងខូចតាហានគ្រានេះ
ក៏តាលគំនិតសោះ លុះឃើញគៀនស៊ីឲ្យសំបុត្រមកយើងដូច្នេះ ឧបមា
បីដូចកៃ្ខកងងឹត ហើយមានគេនាំបង្ហាញផ្លូវឲ្យដើរទៅបាន" និយាយ
ហើយក៏ឲ្យចាត់ចែងតាហានត្រៀមទុក ៗ

ឡេវហ៊្វូនិយាយថា លីប៉ោនោះមិនជាអ្នកចេះគិតគូរក៏មែនហើយ
តែថាបានធ្វើជាមេទ័ពធំមានទីប្រឹក្សាច្រើន ទាំងតាន់កុងក៏មានសតិបញ្ញា
ដែលលោកនឹងជឿស្ដាប់ពាក្យគៀនស៊ី ហើយលើកតាហានទៅធ្វើការ
នោះបើគួរទៅក៏ទៅចុះ តែឲ្យមានដំរិះគិតប្រយ័ត្នការឲ្យមាំមួន បើនឹង
លើកតាហានទៅត្រូវចែកជា ៣ កង; ២ កងឲ្យបំរុងទុកក្រៅស្រុកជាទ័ព

សុទ្ធប់, មួយកង់ទៀតឲ្យលើកចូលទៅធ្វើការជាមួយនឹងខ្លួន ហើយឲ្យ
រាំងស្តាប់ដំណឹងល្អអាក្រក់សិន បើឃើញមិនពិតដល់លោកក៏ឲ្យទាហាន
១ កង់នោះចេញមកវិញ ។ ឫទ្ធបានស្តាប់ហើយក៏យល់ព្រមផង ទើប
ចាត់ទាហានចែកជា ៣ កង ហើយលើកចេញទៅដល់ស្រុកប៉ាក់អៀង
ក្រឡេកទៅឃើញទង់សផោតនៅមាត់ទ្វារខាងលិច ជាសំគាល់ដូចពាក្យ
គៀនស៊ីថា ។

លុះដល់ពេលពាក់កណ្តាលអាធ្រាត្រ ហោសេងក៏លើកទាហាន
ចេញមកជាកងមុខ កោស៊ុនជាកងក្រោយ បើកទ្វារទិសឯកើតចេញទៅ
តបរាំងនឹងកងទ័ពឫទ្ធ ។ ឲ្យគៀនអ៊ុយចេញមកតទល់គ្នា នឹងហោសេង
ជាពន្លឹក ហោសេងបែកទ័ពត្រឡប់ថយក្រោយ កោស៊ុនក៏នាំគ្នាថយ
បណ្តាយចូលបន្ទាយវិញ គៀនអ៊ុយបរបណ្តោញសេះតាមទៅទល់នឹង
ជើងកំពែង ទទួលអ្នកបំរើគៀនស៊ីកាន់សំបុត្រចេញទៅខាងទ្វារទិសឯលិច
យកទៅឲ្យឫទ្ធៗលាមើលឃើញសេចក្តីថា ពេលអាធ្រាត្រយប់នេះ ខ្ញុំបាទ
គៀនស៊ីនឹងបើកទ្វារទិសឯលិចចេញច្បាំង បើបានឮសំឡេងគងឃ្មោះ ឲ្យ
លើកទាហានបង្រ្កិះចូលទៅជាប្រញាប់ ។ ឫទ្ធក្រែកអរណាស់ ក៏ចាត់ឲ្យ
វ៉ៃហ្វូទូននាំទាហានបង្ការខាងស្តាំ ឲ្យចោហង់រៀបចំផ្លូវខាងឆ្វេង ៗ
ឫទ្ធនឹងវ៉ៃហ្វូអៀន លីគៀន ង៉ាក់ជិន · គៀនអ៊ុយលើកទាហានជាកង
កណ្តាល, ដល់ពេលអាធ្រាត្រវែងនឹក ស្រាប់តែឮសំឡេងគងឃ្មោះ

ខាងក្នុង ឃើញទ្វារឯលិចបើកចំហ ។ ចូឆូគិតនឹងឲ្យលើកទាហានចូល ទៅ, លីតៀនឃាត់ចូឆូថា លោកជាមេទ័ពធំមិនត្រូវបង្ខំលើកទាហានចូល ទៅខ្លួនឯងតែម្ដងទេ ត្រូវតែឲ្យខ្ញុំបាទទទួលអាសាចូលទៅបានហើយ បើ ឃើញការណ៍ល្អសិមលោកលើកចូលទៅចុះ ។ ចូឆូតបថា ដែលមិនឲ្យ យើងចូលទៅជាមួយផងនោះ ឃើញថាទាហានទាំងអស់មិនស្រុះចិត្តគ្នា ធ្វើការទេ ។ ចូឆូបរសេះបន្ទ្រះចូលទៅមុខទាហាន រហូតដល់ពាក់ កណ្ដាលស្រុក មិនឃើញមានមនុស្សដើរទៅមកសោះ ក៏តក់ស្លុតរន្ធត់ មហិមា ឃើញថាជាការណ៍កលឧបាយ ទើបស្រែកហៅទាហាន ទាំងឡាយឲ្យស្រូតរត់ចេញទៅក្រៅវិញ, ស្រាប់តែឮសំឡេងផាវទឹងគង ឃ្មោះស្រែកហ៊ោរំពងអឺងកងជុំវិញ ភ្លើងឆេះឡើងគ្រប់ទ្វារទាំង ៤ ទិស ពលឆេះផ្ទះសំបែងអ្នកស្រុកពេញទីបរិវេណភ្លឺដូចថ្ងៃ ។

ហេប៉ាក៏បរសេះស្ទុះទៅដេញតាមកងទ័ពចូឆូពីទិសឯកើត, តៀវលៀវ បរសេះស្ទុះទៅដេញកាប់កងទ័ពចូឆូពីទិសឯលិចខ្ទប់ប្រសព្វគ្នា ។ ចូឆូ ឃើញច្បាស់ភ័យណាស់បរសេះរត់តម្រង់ទៅទិសឯជើង ប្រទះទ័ពឡាន ប៉េង ហោសេង បរសេះដេញទាហានបំពានមកស្កាក់ពីមុខ, ចូឆូបរសេះ ត្រឡប់រត់តម្រង់ទៅទិសឯត្បូង ប្រទះទ័ពកោស៊ុន ហោសេង ចេញ មកស្កាក់ពីមុខទៀត ។ តៀនអ៊ុយតាមចូឆូទៅ ឃើញដូច្នោះក៏បរសេះ ទំលុះទៅប្រយុទ្ធគ្នានឹងទាហានកោស៊ុន ហោសេង ចេញទៅខាងក្រៅ

ស្រុកបាន លុះគ្រឡេកមើលមកក្រោយមិនឃើញប្អូន ក៏ភ័យស្ទុះវិល ត្រឡប់ចូលទៅដល់មាត់ទ្វារ ជួបនឹងលីតៀនសួរថា អ្នកបានឃើញប្អូនដែរឬទេ? ។ លីតៀនឆ្លើយថា ខ្ញុំក៏តាមរកដែរ តែមិនដឹងប្អូននៅត្រង់កន្លែងណា ។

តៀនអ៊ុយថា "អ្នកត្រូវខំប្រឹងស្កាត់ប្រមូលទាហានរបស់យើង ដែលរត់ចេញទៅបាននោះកុំឲ្យបែកខ្ញែកគ្នា ខ្ញុំនឹងវិលទៅរកប្អូន" ថាហើយក៏ស្ទុះប្រងះទាហានលីប៉ោចូលទៅស្វែងរកប្អូនក្នុងស្រុក លុះមិនជួបប្រទះក៏ពុះពារទាហានចេញទៅដល់ស្ពានក្លោះកំពែងស្រុក ជួបនឹងឆាក់ជិនៗ សួរតៀនអ៊ុយថា ជួបប្រទះនឹងប្អូនឬទេ? ។ តៀនអ៊ុយឆ្លើយថា ខ្ញុំស្វែងរក ២-៣ ត្រឡប់ហើយមិនជួបប្រទះសោះ ។ ឆាក់ជិនបបួលតៀនអ៊ុយត្រឡប់វិលទៅដល់ទ្វារស្រុក ទាហានលីប៉ោដែលនៅលើសែនយកភ្លើងគប់អុជឈ្នួនទម្លាក់ចុះមក, ឆាក់ជិនភ័យស្លុតក៏ញាក់សេះថយចេញមកវិញ ឯតៀនអ៊ុយបរសេះស្ទុះទំលាយភ្លើងចូលទៅបានស្វែងរកប្អូនក្នុងស្រុក ។

ឯប្អូនកាលភ្លាត់បែកចាកគ្នាពីតៀនអ៊ុយនោះ ក៏បរសេះពុះទំលាយភ្លើងរត់ទៅផ្លូវទិសឯជើង ជួបប្រទះនឹងលីប៉ោកាន់ទួនបរសេះមក ប្អូនខ្លាចក៏លើកដៃឆ្វេងឡើងបាំងមុខ ដៃស្តាំកាន់បង្ហៀរសេះបរពុះទំលាយភ្លើងទៅដល់មុខលីប៉ោៗ ឃើញមិនច្បាស់ស្មានថា ទាហានរបស់ខ្លួនក៏យកទួនគោះក្បាលប្អូនហើយសួរថា? ឃើញប្អូននៅខាងណា? ។ (មាន៨)

# ព្រះរាជពង្សាវតារប្រទេសកម្ពុជា

## ភាគទី ២

### សម័យនគរធំ

### ឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម រៀបរៀង

(តមក)

មានសិលាចារឹកហៅថា: "ប្រកាសពេទ្យព្យាបាល" សំដែងថា ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់បានសាងមន្ទីរព្យាបាលរោគ សម្រាប់ព្យាបាលរោគសាធារណជន ចំនួន ១០២ អន្លើ ។ មន្ទីរព្យាបាលទាំងនេះ តាំងនៅរៀងរាយតាមបរិវេណក្រុង និងមាននៅតាមខេត្តក្រៅខ្លះផង ។ គេបានស្រាវជ្រាវរកទីតាំងមន្ទីរព្យាបាលអំបាលនេះ តែមិនប្រទះឃើញស្នាមសោះ ទើបសន្និដ្ឋានថា ប្រហែលជាធ្វើដោយឥដ្ឋ ឬគ្រឿងឈើបានជារលាយបាត់បង់អស់ទៅ ។ មន្ទីរព្យាបាលទាំងនេះនៅក្រោមសេចក្តីប្រសិទ្ធីរបស់ព្រះពុទ្ធ ១ អង្គទ្រង់ព្រះនាមថា ភៃសជ្យគុរុ "គ្រូថ្នាំ"(១) ។ នៅក្បែរមន្ទីរព្យាបាលមែងមានវិហាររបស់ព្រះពុទ្ធភៃសជ្យគុរុ គ្រប់អន្លើ ។

ប្រកាសរបស់មន្ទីរព្យាបាលនោះ ខាងដើមនមស្ការដល់ព្រះរតនត្រ័យ និង សរសើរព្រះបារមីរបស់ព្រះមហាក្សត្រិយ៍ ស្រេចហើយ

---

១ ព្រះពុទ្ធភៃសជ្យគុរុនេះ មាននៅតែក្នុងគម្ពីររបស់គណៈមហាយាន គេនិយមថាជាព្រះគ្រូដែលប្រសិទ្ធថ្នាំឲ្យដល់អ្នកមានជម្ងឺ, នៅប្រទេសចិននិងទីបេតនិយមគប់អានព្រះពុទ្ធនេះច្រើន ។

ទើបនិយាយអំពីកិច្ចការក្នុងមន្ទីរព្យាបាលពេគថា "មនុស្សទាំង ៤ ពួកអាចនឹងចូលទៅឲ្យគេរក្សាពេគរបស់ខ្លួនក្នុងទីនេះបានត្រប់ៗ គ្នា ; ទីនេះមានត្រូពេទ្យ ២ នាក់ ក្នុងពេទ្យម្នាក់ៗ មានមនុស្សនៅក្រោមបង្គាប់ជាច្រើន គឺប្រុសម្នាក់ស្រីពីរនាក់ ដែលត្រូវបានទីលំនៅក្នុងទីនោះ, នាយឃ្លាំងពីរនាក់ មានមុខការត្រូវចែកថ្នាំ, ចុងភៅពីរនាក់, អ្នកបំរើពីរនាក់សម្រាប់រៀបដង្វាយព្រះ អ្នកព្យាបាលពេគ ១៤ នាក់ត្រូវចែកថ្នាំឲ្យអ្នកជម្ងឺ, ស្រី ៦ នាក់ ជាអ្នកបុកថ្នាំនឹងដាំទឹកក្ដៅ, ស្រីពីរនាក់ទៀតសម្រាប់បុកស្រូវ, រួមស្រីទាំងអស់ ៨ នាក់ ដែលត្រូវបានទីលំនៅក្នុងមន្ទីរព្យាបាលគឺក្នុង ១ បន្ទប់ពីរនាក់, មនុស្សដែលត្រូវបានទីលំនៅក្នុងពេងព្យាបាលរួមទាំងអស់ ៣២ នាក់ ។ នៅមានអ្នកបំរើ ៦៦ នាក់ទៀត ដែលនៅដោយចេញសោហ៊ុយខ្លួនឯង រួមអ្នកទាំងនេះផង ត្រូវ ៩៨ នាក់ ។

អង្ករសម្រាប់ធ្វើគ្រឿងបូជា កំណត់ក្នុង ១ ថ្ងៃ ១ ថាំង, សល់ពីបូជាទាំងប៉ុន្មាន ត្រូវឲ្យទៅអ្នកជម្ងឺ ។ របស់ទាំងពួងដែលត្រូវបើកពីឃ្លាំងហ្លួងកំណត់ក្នុង ១ ឆ្នាំ ៣ ដង ។ ត្រង់នេះមានពាយឈ្មោះវត្ថុជាច្រើនគឺទឹកឃ្មុំ ស្ករ ក្រមួន ល្ង គ្រឿងទេស តៃឡាត់ខ្មៅ ឡាវហាវ ពាំនស៊ុយផាក់ដី ក្រវាញ ខ្ញី សំបោរល្វែង ផ្ចិតទឹកខ្មេះធ្វើពីផ្លែពុទ្រា; របស់ទាំងនេះសុទ្ធតែរាល់ប្រគល់ឲ្យដោយទៀងទាត់ ។

សិលាចារិកនៅប្រាសាទតាព្រហ្ម ក៏មាននិយាយដល់ការសាងមន្ទីរព្យាបាលពេគទាំង ១០២ ក្នុងឆ្នាំ ព. ស. ១៧២៩ ទាំងមានពាយរាប់ពីវត្ថុ

ផ្សេងៗ ដែលត្រូវប្រើក្នុងមន្ទីរពេទ្យបាលដែរ តែមានចំនួនទ្វេឡើងជាច្រើន គឺគុណជា ៣×១០២ ។ ដូច្នេះ ឃើញថា ក្រសួងពេទ្យគិលានបាលក្នុង ១ ឆ្នាំ អស់ស្រូវ ១១.១៩២ តោន ត្រូវភូមិទាំង ៨៣៨ សឹងមានមនុស្ស ៨១.៦៤០ ជាអ្នកចេញ, មន្ទីរពេទ្យបាលទាំងអស់ប្រើអស់ៈ ល្ង ២.១២៤ គីឡូក្រាម, ក្រវាញ ១០៥ គីឡូក្រាម, គ្រាប់តែឡាត់ ៣.៤០១ គ្រាប់, ថ្នាំគ្រន ៤៨.០០០ គ្រាប់, ថ្នាំបិទបូសដូងបាទ ១.៨៦០ ប្រអប់, របស់ឯទៀតក្រៅពីប៉ុន្មានមុខនេះ ដូចគ្នាក្នុងប្រកាសពេទ្យបាលមុន ។

ការដែលព្រះបាទជយវរ្ម័នទី ៧ ទ្រង់ទំសាងមន្ទីរពេទ្យបាលច្រើនដល់ម្ល៉េះ ក្នុងប្រកាសពេទ្យបាលមានសំដែងអំពីទឹកព្រះរាជហឫទ័យថា ទ្រង់ប្រឈួនដោយរោគរបស់បណ្ដាប្រជា ធ្ងន់ជាងព្រះរោគផ្ទាល់ព្រះអង្គទៅទៀត, ទ្រង់មានព្រះរាជហឫទ័យ ពេញទៅដោយមេត្តាករុណា ដែលជាព្រហ្មវិហារធម៌, ទ្រង់ធ្វើអ្វីៗក៏ដើម្បីសេចក្ដីសុខ-ចំរើនដល់លោកទាំងមូល ទ្រង់តាំងប្រណិធានថា បណ្ដាសត្វទាំងអស់ដែលលិចលង់ក្នុងសមុទ្រគឺវដ្ដសង្សារ សូមឲ្យខ្ញុំអាចស្រោចស្រង់បាន ដោយអំណាចបុញ្ញកិរិយាវត្តនេះ សូមឲ្យក្សត្រិយ៍ទាំងឡាយគ្រប់ព្រះអង្គ ក្នុងកម្ពុជប្រទេសដែលប្រតិព័ទ្ធដោយសេចក្ដីល្អ ហើយដែលជាអ្នកជួយថែទាំគាំរក្សារបស់ដែលខ្ញុំកសាង, បានដល់នូវទីដែលផុតពាកទុក្ខដែលឥតជម្ងឺកាត់ ព្រមទាំងព្រះរាជវង្ស ព្រះអគ្គមហេសី សេនាមាត្យនឹងមិត្រសំឡាញ់រួមជាតិទាំងអស់ ៗ នេះហើយជាឧត្តមគតិរបស់ព្រះមហាក្សត្រិយ៍ អ្នកគ្រប់គ្រងផែនដីៗ

**ការព្រះសាសនា** — សាសនាក្នុងប្រទេសកម្ពុជាក្នុងរជ្ជកាលនេះ មានទាំងសាសនាព្រាហ្មណ៍ ទាំងព្រះពុទ្ធសាសនា ។ ឯព្រះពុទ្ធសាសនា មានទាំងលទ្ធិមហាយាន ទាំងលទ្ធិហីនយាន, តែលទ្ធិមហាយានរុងរឿងជាងលទ្ធិដទៃទាំងអស់ ។ ព្រះបាទជ័យវរ្ម័នទី ៧ នឹងព្រះអគ្គមហេសី ទ្រង់និយមរាប់អានលទ្ធិមហាយានជួនជាងលទ្ធិទាំងពួង ទាំងពីរព្រះអង្គ ទ្រង់ជ្រួតជ្រាបគតិធម៌ក្នុងលទ្ធិមហាយានយ៉ាងជ្រៅជ្រះ ដូចមានពោលមកខាងដើមខ្លះហើយ, ទ្រង់បានឧបត្ថម្ភព្រះពុទ្ធសាសនាឲ្យចំរើនរុងរឿងជាយ៉ាងខ្លាំង, ទ្រង់បានសាងថាវរវត្ថុស្ថានក្នុងព្រះពុទ្ធសាសនា ដូចយ៉ាងព្រះពុទ្ធរូបនឹងព្រះអារាមជាយ៉ាងច្រើន ។ មិនតែប៉ុណ្ណោះ ក្នុងគតិមហាយានមានសេចក្តីនិយមថា បុគ្គលរាល់រូបត្រូវតែកសាងប្រាថ្នាជាពោធិសត្វ - ពុទ្ធភូមិគ្រប់ៗគ្នា ដើម្បីនឹងបានស្រោចស្រង់សត្វលោកដាក់ទៅត្រើយ គឺព្រះនិព្វាន ។ ចំពោះក្នុងរឿងនេះ ព្រះបាទជ័យវរ្ម័នទី ៧ អ្នកមានព្រះរាជហឫទ័យធំទូលាយ ទ្រង់ក៏បានសាងព្រះបារមីជាពុទ្ធភូមិ ទាំងបានសាងព្រះពុទ្ធរូប ធ្វើព្រះអង្គ ប្រតិស្ឋាននៅក្នុងប្រាសាទកណ្តាលក្រុង នឹងនៅទីដទៃខ្លះទៀត, ព្រះពុទ្ធរូបអង្គនេះជាព្រះពុទ្ធរូបធម្មតា គ្រាន់តែសំគាល់ថា "ព្រះឆ្វងព្រះអង្គ" ដោយសេចក្តីគឺថា ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់តាំងព្រះអង្គជាព្រះពុទ្ធតាំងពីក្នុងបច្ចុប្បន្ននេះទៅ ។ វេលាក្រោយមកគេបានតែលក្ខណៈព្រះពុទ្ធរូបឆ្វង

ព្រះអង្គនុះ ទៅជាព្រះពុទ្ធរូបទ្រង់គ្រឿង គឺទ្រង់គ្រឿងជាព្រះពុទ្ធពាក់កណ្ដាលជាព្រះរាជាពាក់កណ្ដាល, គេហៅព្រះពុទ្ធរូបបែបនេះថា "ព្រះពុទ្ធរាជ", តែតាមពាក្យសាមញ្ញហៅថា "ព្រះពុទ្ធរូបទ្រង់គ្រឿង" ។ ដូច្នេះ គប្បីឲ្យដឹងថា ទំនៀមសាងព្រះពុទ្ធរូបបែបនេះក្នុងប្រទេសកម្ពុជា មានមកពីត្រឹមរជ្ជកាលព្រះបាទជយវរ្ម័នទី ៧ នេះ ។ ចំណែកព្រះអគ្គមហេសីរបស់ព្រះអង្គ បានកសាងព្រមទាំងប្រាជ្ញាជា "ព្រះនាងប្រជ្ញាបារមិតា" ។ ព្រះបរមរូប "នាងប្រជ្ញាបារមិតា" នេះ មានព្រះពុទ្ធរូបនៅត្រង់ព្រះនលាដ:ជាសំគាល់ ។

មកក្នុងចុងរជ្ជកាល ព. ស. ១៧៤៤ (គ. ស. ១២០១) នេះ ទ្រង់បានតែងរាជទូត ឲ្យនាំព្រះរាជសារទៅសុំចងសម្ពន្ធមេត្រីភាពនឹងប្រទេសចិន, ប្រទេសចិនក៏បានទទួលជាសម្ពន្ធមេត្រីផង ។ ប្រទេសកម្ពុជាបានចងសម្ពន្ធមេត្រីភាពជាមួយប្រទេសចិន រាប់ជាគ្រាទី ៦ ក្នុងរជ្ជកាលនេះ ។

ព្រះបាទជយវរ្ម័នទី ៧ គង់នៅក្នុងរាជសម្បត្តិបានត្រឹម ២៥ ឆ្នាំ បើរាប់ឲ្យពេញ ប្រមាណ ២៣ ឆ្នាំ ប៉ុណ្ណោះ, តែព្រះរាជករណីយដែលទ្រង់បានធ្វើឲ្យជាប្រយោជន៍ដល់ប្រទេសជាតិ មានច្រើនជាបំផុតជាងព្រះមហាក្សត្រិយ៍ទាំងឡាយ ក្នុងអតីតកាល ។ ពោលចំពោះតែការធំសំខាន់ៗ គឺ:

១ – ទ្រង់កម្ចាត់បច្ចាមិត្រពួកចាមសត្រូវ ទាំងក្នុងប្រទេសទាំងខាងក្រៅឲ្យរាបទាបទៅ ឲ្យកើតសាន្តត្រាណឡើងវិញ ។

២ – ទ្រង់បានពង្រីកព្រះរាជអាណាខេត្តដែលរួមចុះក្នុងរជ្ជកាលមុនៗ នោះ ឲ្យធំទូលាយដល់ខ្នាតដើមស្មើក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ២ ។

៣ – ទ្រង់បានពង្រីកសាងកំពែងក្រុងនគរធំនឹងគូរជុំវិញ ឲ្យល្អមាំនឹងធំទូលាយជាងមុន ។

៤ – ទ្រង់បានសាងប្រាសាទសិលាទុកជាគ្រឿងលំអក្នុងប្រទេស ច្រើនជាងក្នុងរជ្ជកាលមុនៗ, ទ្រង់បានសាងមន្ទីរពេទ្យបាលរោគយ៉ាងធំៗ មានដល់ ១០២ អន្លើ គួរជាគម្រាប់ដល់អ្នកគ្រប់គ្រងប្រទេសទាំងឡាយ គប្បីយកយ៉ាងតាមៗ

៥ – ទ្រង់ព្រមទាំងព្រះអគ្គមហេសី បានទំនុកបម្រុងព្រះពុទ្ធសាសនាក្នុងប្រទេស ឲ្យចំរើនឡើងជាថ្មីម្ដងទៀត, ក្នុងរជ្ជកាលនេះ ទ្រង់ទុកដាក់ព្រះពុទ្ធសាសនាជាសាសនាសម្រាប់រដ្ឋ ។ ចំពោះខាងសាសនាព្រាហ្មណ៍ ទ្រង់ក៏និយមខ្លះដែរ ទៅតាមរាជប្រវេណី ។

អំពីព្រះគុណសម្បត្តិផ្សេងទៀត ព្រះបាទជ័យវរ្ម័នទី ៧ នេះ ទ្រង់មានព្រះរូបធំខ្ពស់រាងស្វាហាប់, កាលពីកុមារទ្រង់បានសិក្សាវិជ្ជាផ្សេងៗ ស្ទើរតែគ្រប់យ៉ាង ; វិជ្ជាដែលទ្រង់ជ្រួតជ្រាបជ្រៅជ្រះគឺគតិធម៌ក្នុងព្រះពុទ្ធសាសនា លទ្ធិធម៌ក្នុងសាសនាព្រាហ្មណ៍, វិទ្យាសាស្ត្រនឹងយុទ្ធ-សាស្ត្រ ។ ព្រះអង្គមានព្រះកាយធំខ្ពស់រាងស្វាហាប់មានព្រះរាជហឫទ័យធ្ងន់ មានព្រះអធ្យាស្រ័យប្រកបដោយព្រហ្មវិហារធម៌ជានិច្ច ទ្រង់មាន

ព្រះវិរិយៈយ៉ាងក្លា, ការអ្វីដែលទ្រង់ប៉ងនឹងធ្វើហើយ ទោះបីលំបាកយ៉ាងណា ក៏ទ្រង់ព្យាយាមធ្វើទាល់តែសម្រេចៗ លុះឆ្នាំ ព.ស. ១៧៤៨ ទ្រង់សោយទិវង្គតដោយអំណាចជរាភាព, លុះទិវង្គតហើយ គេថ្វាយព្រះនាមព្រះបរមសព្វថ្ងៃចម្តេចមិនប្រាកដ ៗ ព្រះមហាក្សត្រិយ៍នេះ រាប់ជា "រាជាធិរាជ" ១ អង្គក្នុងប្រវត្តិសាស្ត្រ ៗ (ម.ឥត)

> អ្នករៀនកុំរៀនៗទៅ ត្រូវតាំងចិត្តជងជា:
>
> រៀនថៃហ្នឹង ចាំថៃហ្នឹង យល់ថៃហ្នឹង,
> ចាំដោយប្រឹង ខំទន្ទេញ ខំហាត់ថា,
> យល់ដោយប្រឹង គិតសង្កេត ពិចារណា,
> ចាំនឹងយល់ លោកហៅថា ការរៀនចេះ ៗ
> ចេះត្រូវផ្សង់ ខំត្រមង់ សោតវិញ្ញាណ
> ព្រមទាំងមាន ស្មារតីមាំ ត្រងចំណេះ
> គ្រូប្រាប់អ្វី គប្បីចាំ រូបត្រិះរិះ
> រៀនឲ្យចេះ ឲ្យចេះឆាប់ ឲ្យចិតថេរ ៗ
> ឃើងកុំខ្ជិល ឃើងខ្មើមខ្ជិល ឃើងខ្លាសខ្ជិល,
> ខ្ជិលមន្ទិល នាំឲ្យក្មេច នាំថោកក្មេ,
> ឃើងឧស្សាហ៍ ក្នុងការរៀន កុំទំនេរ
> ទើបបំបែរ កែអង្គខ្លួន ជាប្រាជ្ញប្អាន ៗ
>
> យ. អ.

# រឿងអាស្ចារ្យថ្លែងរឿងម្ភៃប្រាំ

## លោក សាង-សារ៉ាត លេខានុការក្រសួងហិរញ្ញវត្ថុ

ប្រែពីភាសាបារាំងមកជាខ្មែរ

ព្រះបាទគន្ធព្វសេន (Gandbarb.Sên) ព្រះចៅនៃទីក្រុងធារានគរ (Dhàrà nagar) មានអគ្គមហេសី៤អង្គនិងបុត្រា ៦ អង្គ សុទ្ធសឹងតែមានប្រាជ្ញា ហើយខ្លាំងម៉ាំមួន ៗ លុះស្តេចអង្គនេះទិវង្គតទៅ, ក្រោយបន្តិចមក បុត្រាច្បងព្រះនាមសហ័ន (Shank) ឡើងសោយរាជ្យ ៗ កន្លងច្រើនថ្ងៃមក ព្រះអនុជរបស់ព្រះបាទសហ័នព្រះនាមពិករ័ន (Bikran) បានសម្លាប់ព្រះរៀមទាំងឡាយរបស់ព្រះអង្គគ្មានសល់ ហើយទ្រង់គ្រប់គ្រងរាជ្យប្រកបដោយគតិបណ្ឌិតនិងដោយគន្លងធម៌ ៗ ស្តេចអង្គនេះបានរកអំណាចព្រះអង្គមួយថ្ងៃបន្តិចៗ ទាល់តែថ្ងៃមួយនោះទៅជាព្រះចៅប្រទេសក្នុងទាំងមូល ៗ ហេតុដូច្នេះ ព្រះអង្គបានរៀបចំប្រទេសឲ្យមានឥទ្ធិពលយ៉ាងប្រសើរ ហើយចារិកនាមព្រះអង្គក្នុងដើមសករាជមួយ ៗ

ក្នុងពេលបន្តិចតមក ព្រះអង្គទ្រង់ព្រះចិន្តាឃើញថា: ត្រូវតែព្រះអង្គយាងទៅតាមភូមិស្រុក ដើម្បីនឹងទ្រង់ព្រះសណ្តាប់កិច្ចការក្នុងប្រទេស ៗ លុះទ្រង់ព្រះចិន្តាសម្រេចយ៉ាងដូច្នោះហើយ ទើបប្រគល់រដ្ឋាភិបាលទៅព្រះអនុជរបស់ព្រះអង្គ ព្រះនាមពថ៌រ៍ (Barthari) ហើយ

ទ្រង់ព្រះផ្នួសប្រព្រឹត្តជាអ្នកធុតង្គ រួចទ្រង់យាងតែមួយព្រះអង្គឯងពីស្រុកមួយទៅស្រុកមួយ នឹង ពីព្រៃមួយទៅព្រៃមួយ ។

មានព្រាហ្មណ៍ម្នាក់ជាអ្នកសូមនៅទីក្រុងនោះ ។ ថ្ងៃមួយទេវតាបានយកផ្លែ "កាល់" មួយមកឲ្យព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍លុះបានផ្លែឈើនោះយកទៅផ្ទះហើយនិយាយប្រាប់ប្រពន្ធថា: "កាលទេវតាឲ្យផ្លែនេះមកបង លោកប្រាប់ថា: បើអ្នកណាបរិភោគផ្លែនេះ អ្នកនោះលែងស្លាប់" ។ ព្រាហ្មណីលុះឮដូច្នោះ យំសោកជាខ្លាំង ។ នាងនិយាយថា: "ឱ! របស់នេះជាទុក្ខមួយយ៉ាងធ្ងន់របស់យើង ព្រោះថាបើយើងលែងស្លាប់ តើដល់កាលណាទៅទើបយើងឈប់សុំទានគេ, ហេតុដូច្នោះស្លាប់វិញល្អជាង! លុះស្លាប់ទៅ យើងនឹងផុតពីទុក្ខព្រួយលំបាកនេះពុំខាន" ។ ព្រាហ្មណ៍និយាយឡើងវិញថា: "បងបានយកផ្លែនេះមកឲ្យប្អូន ប៉ុន្តែពាក្យសំដីរបស់ប្អូន នាំឲ្យបងវង្វេងអស់, បើដូច្នោះចូរប្អូនប្រាប់បងមើល តើឲ្យបងធ្វើយ៉ាងណាវិញក្នុងពេលនេះ?" ។

ព្រាហ្មណីនិយាយប្រាប់ប្ដីថា: យកផ្លែនេះទៅថ្វាយស្ដេចទៅ បងនឹងបានរង្វាន់ដែលអាចធ្វើឲ្យយើងបានស្គាល់ នូវសេចក្ដីសប្បាយទាំងលោកនេះនឹងលោកខាងមុខ ។

លុះបានឮយ៉ាងដូច្នោះហើយ ព្រាហ្មណ៍បានចូលទៅជិតព្រះមហាក្សត្រ ហើយបានទាំងថ្វាយពរសព្វសាធុការដល់ព្រះអង្គផង ។

រួចព្រាហ្មណ៍ក៏បាននិទានអំពីគុណសម្បត្តិនៃផ្លែឈើចំឡែកនោះ ក្រាបទូលស្ដេចថា: "សូមទ្រង់ព្រះមេត្តាប្រោស ! សូមព្រះអង្គយកផ្លែឈើនេះចុះ ហើយសូមប្រទានតែទ្រព្យសម្បត្តិមកទូលបង្គំខ្ទះបានហើយ ព្រោះទូលបង្គំពេញចិត្តណាស់ ត្រង់ការឃើញព្រះអង្គទ្រង់គង់ព្រះជន្មយឺនយូរ" ។ ព្រះមហាក្សត្រទ្រង់ប្រទានប្រាក់ មួយពាន់រៀលកហាបនៈ ហើយទ្រង់បើកឲ្យព្រាហ្មណ៍ចេញមកវិញ រួចទ្រង់យាងចូលទៅក្នុងបន្ទប់ក្រឡាព្រះបន្ទំរបស់ព្រះអង្គ ។ ស្ដេចទ្រង់មានព្រះបន្ទូលហៅឯកអគ្គមហេសី ដែលទ្រង់សព្វព្រះរាជហឫទ័យជាងគេមកជិតព្រះអង្គ ហើយទ្រង់ប្រទានផ្លែឈើនោះដោយព្រះរាជឱង្ការថា: "បរិភោគផ្លែនេះទៅប្អូនសំឡាញ់! ដើម្បីឲ្យប្អូនបានរស់ជីវិតរហូតតទៅផង ដើម្បីឲ្យប្អូននៅក្នុងតរុណវ័យដរាបទៅផង" ។ លុះបានឮព្រះរាជឱង្ការដូច្នោះ ឯកអគ្គមហេសីក៏បានទទួលយកផ្លែឈើនោះ ។ បំណែកខាងព្រះរាជា ក៏ស្ដេចយាងចូលទៅក្នុងព្រះទីនាំងចុងកែងទៅ ។ ព្រះនាងបានយកផ្លែនោះទៅឲ្យនាយកងក្រវែលម្នាក់ដែលព្រះនាងស្គាល់ ។ ឯនាយកងក្រវែលបានឲ្យផ្លែនោះទៅស្រីស្នំម្នាក់ដែលខ្លួនស្គាល់ ហើយបានពន្យល់ពីគុណសម្បត្តិនៃផ្លែនោះផង ។ នារីនោះគិតថា 'នេះជាវត្ថុមួយដែលសមនឹងបុណ្យស្ដេចពិត" ទើបនាងយកផ្លែនោះទៅថ្វាយព្រះមហាក្សត្រ ។ ទ្រង់ក៏បានឲ្យនាងត្រឡប់មកលំនៅវិញ បានទាំងប្រទានទ្រព្យសម្បត្តិជា

ព្រែទឲ្យនាងនោះផង ។ កាលព្រះអង្គទ្រង់ទតផ្លែនោះ ទ្រង់ព្រួយព្រះហឫទ័យធុញទ្រាន់នឹងលោកិយនេះពេក ទើបទ្រង់មានព្រះរាជឱង្ការថា: "វត្ថុដែលអាចវិនាសសាបសូន្យនៃលោកនេះ ហើយដែលនាំឲ្យយើងធ្លាក់ទៅសោយទុក្ខក្នុងនរកនោះ តើមានប្រយោជន៍អ្វី? ត្រូវតែយកផ្លូវសមណៈ រស់នៅតាមគំនិតរបស់ព្រះវិញ នោះនឹងបានដល់សម្បត្តិនិព្វានពុំខាន" ។ លុះទ្រង់ព្រះតម្រិះដូច្នោះ ទ្រង់ក៏យាងចូលក្នុងព្រះរាជបន្ទំ ហើយទ្រង់សួរព្រះអគ្គមហេសីថា: តើនាងយកផ្លែ "កាល់" ដែលទ្រង់ប្រទាននោះទៅឯណាទៅ"? ។ ព្រះនាងទូលតបថា: "ទូលព្រះបង្គំបរិភោគហើយ" ។ ព្រះរាជាទ្រង់បង្ហាញផ្លែនោះ ។ លុះឃើញដូច្នោះ ព្រះនាងក៏តក់ស្លុត ឥតនឹកឃើញពាក្យដែលគួរទូលតបសូម្បីតែមួយម៉ាត់ឡើយ ។ ព្រះរាជាយាងចេញមកវិញ ទ្រង់ដុសលាងផ្លែនោះ ហើយទ្រង់សោយទៅ ។ បន្ទាប់មក ទ្រង់លះបង់រាជសម្បត្តិទៅទ្រង់ព្រះផ្នួស ដោយឥតមានព្រះរាជឱង្ការប្រាប់អ្នកណា ឬ ស្ដាប់អ្នកណាសោះ ទ្រង់យាងចូលទៅគង់នៅក្នុងព្រៃ ។

រាជសម្បត្តិស្ដេចពិក្រ័ទក៏នៅទំនេរ ។ ព្រះឥន្ទបានជ្រាបដំណឹងនោះ ទើបទ្រង់បង្គាប់ឲ្យអារក្សចុះមកការពារនគរ ។ ឯអារក្សក៏បានមកនៅថែរក្សាទីក្រុងនោះទាំងយប់ទាំងថ្ងៃ ។

ឯដំណឹងថាស្ដេចពាថរ៍ (Barthari) ចេញចាកចោលព្រះរាជសម្បត្តិនេះ ក៏លេចឮឡើងសុះសាយក្នុងព្រះរាជអាណាចក្រ ។

លុះកាលណាទ្រង់ជ្រាបដូច្នេះ ព្រះបាទពិករនក៏ទ្រង់យាងយ៉ាងប្រញាប់មកកាន់ព្រះរាជអាណាចក្រព្រះអង្គវិញ ។ ទ្រង់យាងមកដល់ក្នុងវេលាយប់ ។ ក្នុងពេលដែលទ្រង់យាងមកដល់ទីក្រុង អារក្សស្រែកឃាត់ព្រះអង្គថា: "ឯងជាអ្នកណា ? ឯងទៅឯណា ? ចូរឯងឈប់សិនហើយចូរប្រាប់ឈ្មោះយើង? ។ ព្រះបាទពិករនតបថា: "យើងជាស្តេចពិករ័ន យើងត្រឡប់ចូលក្នុងព្រះរាជធានីរបស់យើងវិញ ឯងជាអ្វីដែលមកឃាត់យើងនេះ? ។

អារក្សឆ្លើយថា: "យើងជារាជទូតរបស់ព្រះ, មកនៅទីនេះ ដើម្បីមើលរក្សាព្រះរាជធានីនេះ, បើឯងពិតជាស្តេចពិករ័នមែន ចូរឯងប្រយុទ្ធជាមួយយើងសិន រួចចាំឯងចូលទៅក្នុងព្រះរាជធានីជាក្រោយ" ។

លុះទ្រង់ឮដូច្នេះ ស្តេចក៏ទ្រង់រឹតព្រះកដិ ហើយទ្រង់ប្រឹងប្រយុទ្ធនឹងអារក្ស ។ ឯអារក្សបែរមុខមករកព្រះអង្គ រួចការប្រយុទ្ធក៏ផ្តើមឡើង ។ ក្រោយបង្អស់ ស្តេចវាយអារក្សដួលលើដែនដី ហើយទ្រង់អង្គុយលើដើមទ្រូងវា ។ អារក្សទូលព្រះអង្គថា: "ឱព្រះមហាក្សត្រស្តេចវាយខ្ញុំដួលដេកដីហើយ ! ខ្ញុំសូមទុកជីវិតថ្វាយព្រះអង្គ" ។ ស្តេចក៏ទ្រង់សំណើចថា: "ឯងប្រហែលជាឆ្កួតហើយ តើឯងទុកជីវិតឲ្យអ្នកណា ? បើអញចង់សម្លាប់ឯងនោះ អញអាចសម្លាប់ឯងឥឡូវនេះបាន, តើឯងទុកជីវិតឲ្យអញយ៉ាងណា ?" ។

ឯអាគ្រូនិយាយដូចតទៅនេះថា: "បពិត្រព្រះមហាក្សត្រ! ទូលព្រះបង្គំជួយព្រះអង្គឲ្យផុតអំពីសេចក្ដីស្លាប់, ប៉ុន្តែដំបូងបង្អស់ សូមទ្រង់ស្ដាប់ទូលព្រះបង្គំសិន, ក្រោយទៅទៀត ព្រះអង្គមុខជាទ្រង់បានកាន់បង្កូតទូបទាំងអស់នេះ ដោយឥតព្រួយព្រះរាជហឫទ័យឡើយ" ។

ព្រះមហាក្សត្រទ្រង់លែងអាគ្រូនោះទៅ ទ្រង់ស្ដាប់យ៉ាងប្រុងប្រយ័ត្ន ។ ឯអាគ្រូនិយាយដូច្នេះថា: "នៅក្នុងទីក្រុងនេះ មានស្ដេចមួយព្រះអង្គមានព្រះទ័យល្អណាស់ព្រះនាមចន្ទ្រភាណ (Chandr-Bhan) ។ ថ្ងៃមួយនោះ ស្ដេចអង្គនេះយាងចូលទៅក្នុងព្រៃ បានឃើញអ្នកធុតង្គម្នាក់ព្យួរខ្លួននៅលើដើមឈើ ក្បាលត្រឡប់ចុះមកដីហើយហិតយកផ្សែងជាដកប ។ មនុស្សនេះមិនដែលទទួលអ្វីពីអ្នកណា ហើយមិនដែលនិយាយរកអ្នកណាសោះ ។

លុះស្ដេចបានទតឃើញមនុស្សនោះ ព្រះអង្គទ្រង់យាងត្រឡប់ចូលទៅក្នុងប្រាសាទ ទ្រង់គង់កណ្ដាលព្រះរាជវាំង ហើយមានព្រះរាជឱង្ការថា: "អ្នកណាមួយទៅយកអ្នកធុតង្គនោះមក នឹងបានរង្វាន់មួយពាន់រៀល" ។ ស្រីស្នំមួយពួកលុះឮដូច្នេះ បានចូលទៅជិតព្រះអង្គ ហើយក្រាបទូលថា: "សូមព្រះអង្គទ្រង់បង្គាប់ចុះ ខ្ញុំម្ចាស់នឹងទៅរួមរក្សនឹងអ្នកធុតង្គនោះលុះត្រាតែបានកូនមួយ ហើយទូលបង្គំនឹងនាំមកថ្វាយព្រះអង្គ ហើយឲ្យអ្នកធុតង្គនោះលើកកូនដាក់លើស្មាមកផង" ។

ព្រះមហាក្សត្រទ្រង់បារម្ភនឹងពាក្យសំដីនោះណាស់ ហើយទ្រង់បានឲ្យម្ជុលមួយសន្ទឹកទៅនារីនោះ ដែលជាសញ្ញាបង្ហាញឲ្យឃើញថា: "ព្រះអង្គស្រះស្រួល" រួចទ្រង់បង្គាប់ឲ្យនាងនោះចេញទៅ ។

នាងចូលទៅក្នុងព្រៃ លុះទៅដល់ទីកន្លែងអ្នកធុតង្គនោះ តើនាងឃើញអ្វី? នាងៈឃើញអ្នកធុតង្គព្យួរក្បាលត្រឡប់ចុះមកក្រោម ។ អ្នកធុតង្គនោះឥតបរិភោគ ឥតអាស្រ័យទឹក ហើយខ្លួនកាន់តែស្គុតទៅ ។

នាងដាំបាយយកទៅដាក់ក្នុងមាត់អ្នកធុតង្គនោះ អ្នកធុតង្គក៏លេបបាយនោះ, ហើយនាងក៏ឲ្យបាយតទៅទៀត ។ ចំនួនពីរថ្ងៃតមក នាងតែងឲ្យបាយដល់អ្នកធុតង្គ ។ អ្នកធុតង្គលុះបរិភោគទៅ ក៏មានកំលាំងឡើង ។ អ្នកធុតង្គនោះ លុះបើកភ្នែកឃើញនាងក៏ចុះពីលើដើមឈើ រួចសួរអំពីហេតុដែលនាំឲ្យនាងមកក្នុងទីនេះ ។ នាងឆ្លើយថា: "ខ្ញុំជាកូនទេវតា ខ្ញុំបួសក្នុងស្ថានព្រះឥន្ទ្រ ឥឡូវខ្ញុំមកក្នុងព្រៃនេះ" ។

អ្នកធុតង្គនិយាយថា "ផ្ទះនាងនៅឯណា? ចង្អុលប្រាប់ខ្ញុំមើល" ។ នាងក៏នាំអ្នកធុតង្គនោះទៅផ្ទះនាង, រៀបចំម្ហូបចំណីដែលមានឱជារសតាំង ៦ យ៉ាង ។ ឯអ្នកធុតង្គក៏ឈប់ហឹតផ្សែងហើយតាំងបរិភោគនឹងផឹកទឹករាល់ថ្ងៃ ។ ដល់ចុងបង្អស់ ទេវតាព្រះនាមកាមៈ (Kāma) បានធ្វើឲ្យអ្នកធុតង្គនោះវង្វេងស្មារតី ភ្លេចចម្រើនភាវនា គិតតែត្រេកត្រអាលនឹងតណ្ហា

រួចនាងនោះក៏មានផ្ទៃពោះ ។ ដប់ខែក្រោយមក កូនប្រុសមួយកើតឡើង ។

ចំនួនច្រើនខែកន្លងមកទៀត នាងនោះ និយាយទៅអ្នកធុតង្គថា: "ឱសន្តបុគ្គល! (Saint) ខ្ញុំត្រូវទៅតាំងសីលដើម្បីលុបបាបរបស់យើង" ។ លុះនិយាយអង្វរករួច នាងលើកកូនដាក់លើស្មាគាត់ ហើយដើរតម្រង់ទៅព្រះបរមរាជវាំង ដើម្បីបំពេញកិច្ចសន្យារបស់នាងឲ្យជ្រះស្រឡះ ។ លុះនាងទៅដល់ចំព្រះភក្ត្រព្រះករុណា ដែលទ្រង់ស្គាល់នាងពីចម្ងាយ ហើយដែលទ្រង់ទតឃើញក្មេងម្នាក់នៅលើស្មាអាចារ្យផងនោះ ព្រះអង្គក៏មានព្រះរាជឱង្ការទៅអាមាត្យទាំងអស់គ្នាថា: "ចូរអ្នកទាំងអស់មើល! តើនាងស្មំដែលចេញទៅយកអាចារ្យបានមកមែនឬទេ?" ។ អាមាត្យទាំងអស់ឆ្លើយថា: "សូមទ្រង់ព្រះមេត្តាប្រោស! ព្រះអង្គមានព្រះរាជឱង្ការត្រូវមែន, គឺប្រាកដជានាងនេះហើយ សូមទ្រង់ព្រះរាជទានទោស ដើម្បីឲ្យយើងខ្ញុំព្រះអង្គទាំងអស់បញ្ជាក់ព្រះអង្គថា: អំពើដែលនាងនេះបានសន្យាទាំងប៉ុន្មាន គឺនាងបានធ្វើមកអស់ហើយ" ។

(មានត)

## ដំណើរមកកាន់ប្រទេសកម្ពុជា

# នៃមហាបណ្ឌិត គុណបាលបិយសេន ម៉ាល៉ាល៉ះសេកេរៈ

ជាអធិបតីនៃពុទ្ធិកសមាគមពិភពលោកនៅលង្កាទ្វីប

របស់

# ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

---

លោកម៉ាល៉ាល៉ៈសេកេរៈ ជាជាតិអ្នកលង្កា អាយុ ៥១ ឆ្នាំសម្បុរសណ្តែកបាយ មាឌធាត់ទាបក្រអាញ ភ្នែកនឹងបុកពាសមជាអ្នកសុភាពរាងវៃ លោកជាប្រធាននៃពុទ្ធិកសមាគមពិភពលោកនៅលង្កាទ្វីប ។

កាលពីថ្ងៃទី ២៤ ខែមេសា ឆ្នាំ ១៩៥១ មហាបណ្ឌិតនេះ បានអញ្ជើញចេញពីប្រទេសលង្កាទ្វីបដោយអាកាសយាន សំដៅទៅកាន់ប្រទេសនានា ដែលមានកាន់សាសនាព្រះពុទ្ធដើម្បីទស្សនានូវព្រះពុទ្ធសាសនាក្នុងប្រទេសនោះៗ ។ មុនដំបូង លោកចៀងចូលទៅសិង្គប៉ូរ (មលូកា) ក្រុងក្វាឡាឡាំពួរ (ជ្វា) នឹងពីណាំង រួចហើយលោកមកសំណាក់នៅក្រុងបាំងកកចំនួន ១២ ថ្ងៃ ។ លុះដល់ថ្ងៃទី ១៥ ខែឧសភា លោកចេញពីប្រទេសថៃមកកាន់ខេត្រសៀមរាប ដោយក្បួនរថយន្តដែលរាជការថៃជូនមក ។ នៅថ្ងៃទី ១៦ ខែដដែលនេះ លោកអញ្ជើញទៅទស្សនាប្រាសាទបុរាណទាំងឡាយនៅសៀមរាប ដោយមាន

ទៅហ្វាយខែត្រសៀមកបញ្ជូនដំណើរ ។ លុះដល់ថ្ងៃទី ១៩ ខែ ។ សកា ពេលម៉ោង ៥ កន្លះរសៀល លោកអញ្ជើញមកដល់រាជធានីភ្នំពេញ ដោយក្សេនជូនវថយន្ត ។

# បដិសណ្ឋារកិច្ចចំពោះមហាបណ្ឌិត នៃក្រុមពុទ្ធបរិសទ្យ ភ្នំពេញ

នៅត្រង់ភូមិតាំងចំរេះដែលជាជាយរាជធានីខ្មែរ មានគណៈកម្មការបដិសណ្ឋារៈមួយក្រុម នៃសមាគមមិត្តសាលាបាលី និងពុទ្ធបរិស័ទទាំងប្រុសទាំងស្រីដទៃទៀតជាច្រើន បាននៅរង់ចាំទទួលលោក ។ ក្នុងចំនួននេះ គេសង្កេតឃើញឯកឧត្តម សម - ញាណ រដ្ឋមន្ត្រីក្រសួងធម្មការជាដើមជាអ្នកចាត់ចែងកិច្ចការទទួល ។ លុះមហាបណ្ឌិតមកដល់ភ្លាម ពួកអ្នកចាំទទួលទាំងប្រុសទាំងស្រីនាំគ្នាទៅចោមរោម សំដែងសេចក្តីគួរសមដល់លោក ។ មហាបណ្ឌិតនេះក៏ចេះតែលើកដៃសំពះហើយសំពះទៀត ដល់អ្នកដែលទៅធ្វើបដិសណ្ឋារកិច្ចទាំងប៉ុន្មាន តាមរបៀបពុទ្ធសាសនា គឺគ្មានប្រើការចាប់ដៃតាមបែបអឺរុបទេ ។

ក្នុងពេលនោះ ឯកឧត្តម សម - ញាណ បានថ្លែងស្វាគមន៍ (ដំណើរមកដំប្រពៃ) ហើយបានឆ្លៀតសួរសេចក្តីចាប់អារម្មណ៍របស់លោក ក្នុងការដែលលោកអញ្ជើញទៅមើលប្រាសាទបុរាណរបស់ខ្មែរ ។ មហាបណ្ឌិតមានប្រសាសន៍តបមកវិញ ជាភាសាអង់គ្លេស ដោយមាន

លោកក្រេម៉ង់ ជាអ្នកបកប្រែ ។ លោកថា "ក្បួនច្បាប់របនាយ៉ាងកើតនៃប្រាសាទខ្មែរបុរាណដែលលោកបានឃើញទាំងប៉ុន្មាននោះ មិនមែនគ្រាន់តែនាំឲ្យលោកចង់គយគន់ ដោយពិនិត្យពិច័យយ៉ាងជាប់ចិត្តប៉ុណ្ណោះទេ គឺនាំឲ្យលោកឃើញច្បាស់ដល់វិវឌ្ឍន៍នឹងការចាក់ឫសយ៉ាងមុតមាំនៃពុទ្ធសាសនានៅប្រទេសនេះផង" ។ មហាបណ្ឌិតបានបញ្ជាក់អំពីវត្ថុបំណងនៃបេសកកម្មរបស់លោកថា "គ្មានត្រូវការអ្វីដទៃក្រៅអំពីពិនិត្យកិច្ចការសាសនា ហើយនឹងបបួលប្រទេសដែលកាន់ព្រះពុទ្ធ-សាសនាទាំងឡាយឲ្យសាមគ្គីរួបរួមគ្នា បោះបង់ការប្រកាន់ពួកគណៈចោលទៅ ដើម្បីនឹងបង្កើតមជ្ឈមណ្ឌលភូមិភាគនៃសមាគមពុទ្ធសាសនាគប់ទឹកខ្មែរឡើង" ។ លោកបានបន្ថែមថា "ក្នុងពេលដែលប្រទេសកាន់ពុទ្ធសាសនាទាំងឡាយ មានជីវភាពឡើងជាថ្មីនេះ ការរួបរួមគ្នាដោយឥតប្រកាន់និកាយ នៃពុទ្ធបរិសទ្យក្នុងពិភពលោកទាំងមូល ជាករណីយកិច្ចមួយយ៉ាងសំខាន់ ដែលត្រូវតែខំខ្នះខ្នែងធ្វើ ដើម្បីនឹងញ៉ាំងការប្រស្រ័យរាក់ទាក់គ្នានឹងគ្នា ដែលបានបាត់បង់ទៅជាច្រើនសតវត្សមកហើយនោះ ឲ្យមានរូបរាងឡើងវិញ គឺសាមគ្គីធម៌យ៉ាងមុតមាំនេះហើយដែលនឹងអាចរំលត់ភ្លើងសង្គ្រាម កំពុងតែឆេះដាលរាលសព្វថ្ងៃនេះបាន" ។

បន្ទាប់មក ឯកឧត្ដម សម - ញាណ បានថ្លែងសេចក្ដីរីករាយក្នុងនាមនៃពុទ្ធសាសនិកជនខ្មែរទាំងមូល ចំពោះដំណើរមកដោយស្មោះស្ម័គ្រនៃលោកម៉ាលាល់ៈសេកេរ៉ៈនេះ ។

រួចហើយ លោកហ៊យ-ប៊ុក ជាប្រធាននៃសមាគមមិត្តសាលាបាលី ក៏យកកិច្ចការនៃសមាគមនេះ ដែលបំរុងនឹងបង្កើតពុទ្ធិកសមាគមមជ្ឈមណ្ឌលភូមិភាគមួយ ដែលមានការទាក់ទងគ្នានឹងពុទ្ធិកសមាគមពិភពលោកនោះ ។

លុះសន្ទនាគ្នាស្រេចហើយ រថយន្តចំនួន ៣០ ដែលមានដោតទង់សាសនាជាកិត្តិយសផង ក៏បានជូនដំណើរក្បួនធម្មទូតនេះទៅកាន់មហាសន្នាគារ "ឡឺ រ៉ូយ៉ាល់" ដើម្បីសំរាក ។

# មហាបណ្ឌិតថ្វាយទង់ពុទ្ធសាសនា
# បំពោះព្រះមហាក្សត្រ

លុះដល់ថ្ងៃទី ១៨ ខែមករា ពេលម៉ោង ១០ ព្រឹក មហាបណ្ឌិត ម៉ាឡាឡៈសេកេរ ចូលគាល់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដោយមានឯកឧត្តម នាល-ផែន រដ្ឋមន្ត្រីក្រសួងការពារបរទេសនាំចូលក្រាបបង្គំគាល់ ។

ក្នុងពេលនោះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ធ្វើបដិសណ្ឋារៈ ដល់មហាបណ្ឌិត បានទ្រង់ប្រោសព្រះរាជទានហត្ថសម្ព័ន្ធជាកិត្តិយសដល់លោក ហើយទ្រង់សន្ទនាយ៉ាងរាក់ទាក់អស់ពេលដ៏យូរ ។ មុននឹងក្រាបថ្វាយបង្គំលា, មហាបណ្ឌិតបានថ្វាយទង់ពុទ្ធសាសនាចំពោះព្រះមហាក្សត្រ ។ ទង់នោះគឺអ្នកតំណាងប្រទេសទាំងឡាយ

ដែលកាន់ព្រះពុទ្ធសាសនាគង់ពិភពលោកទាំងមូល ដែលមានប្រទេសកម្ពុជាជាសមាជិកដែរនោះ បានយល់ព្រមបង្កើតឲ្យមានឡើង គង់ទុកាសសន្និសិទពុទ្ធសាសនានៅលង្កាទ្វីប កាលពីថ្ងៃទី ២៥ ខែឧសភា ទៅថ្ងៃទី ៦ មិថុនា ឆ្នាំ គ ស ១៩៥០ ។

ទង់ពុទ្ធសាសនានេះ មាន ៦ ពណ៌ ជាផ្ទាំងបញ្ឈរតំរៀបគ្នាដូច្នេះ គឺផ្ទាំងពណ៌ខៀវ លឿង - ក្រហម - ស - ហង្សបាទ ហើយផ្ទាំងខាងចុងដែលមានទំហំប៉ុនគ្នានឹងផ្ទាំងខាងដើមដែរនោះ ត្រូវតំរៀបពណ៌ដដែលនេះពីលើចុះមកក្រោមដូច្នេះ គឺខៀវ, លឿង, ក្រហម, ស នឹងហង្សបាទ គេហៅថា ពណ៌ផ្ទុក ឬ ពណ៌ចំរុះ ។

ក្រៅពីទង់ពុទ្ធសាសនា ដែលលោកបានថ្វាយជាផ្សារការគង់នាមនៃពុទ្ធិកសមាគមពិភពលោក ដើម្បីសុំឲ្យប្រទេសកម្ពុជាទទួលប្រើប្រាស់ផងនេះ, មានសៀវភៅផ្សេង ៗ ទៀតដែលលោកបានថ្វាយ ចំពោះព្រះមហាក្សត្រ ប្រយោជន៍ជាអនុស្សាវរីយ៍គង់ដំណើររបស់លោក ។

## មហាបណ្ឌិតចូលថ្វាយបង្គំ
## សម្តេចសង្ឃនាយក និង ឧត្តមប្រឹក្សា

នៅពេលរសៀលម៉ោង ១៥ នៃថ្ងៃទី ១៨ ឧសភានោះ លោកបានចូលទៅថ្វាយបង្គំសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក គណៈមហានិកាយនឹងព្រះរាជាគណៈឋានានុក្រម ដែលគង់ចាំទទួលគង់វិហារ

វត្តឧណ្ណាលោម ដោយមានឧបាសកឧបាសិកាចំណុះវត្តមកជួបជុំយ៉ាងកុះករ ។ សម្តេចបានសន្ទនានឹងមហាបណ្ឌិតនេះជាភាសាបាលីដោយឧស្សាសនសព្វ មហាបណ្ឌិតក៏បានថ្លែងតបជាភាសាបាលីដែរ ។

បន្ទាប់មក មហាបណ្ឌិតបានអញ្ជើញទៅថ្វាយបង្គំសម្តេច សុធម្មា-ធិបតី សង្ឃនាយកគណៈធម្មយុត្តវត្តបទុមវតី នឹងសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា ល្វី ឯម វត្តលង្កា ដែលមានព្រះសង្ឃឧបាសកឧបាសិកាជាច្រើន ចាំទទួល ។

## មហាបណ្ឌិតទៅទស្សនាសាលាបាលីជាន់ខ្ពស់

បន្ទាប់មកទៀត មហាបណ្ឌិត អញ្ជើញទៅកាន់មន្ទីរស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ ដែលមានអគ្គរដ្ឋការក្នុងក្រុមនេះ ចាំទទួលលោកយ៉ាងអឹកធឹក ។ លុះលោកទស្សនានូវក្រុមផ្សេងៗ ក្នុងក្រសួងនេះរួចហើយ លោកអញ្ជើញទៅមើលសាលាបាលីជាន់ខ្ពស់ ។ នៅទីនេះព្រះតេជព្រះគុណព្រះភាណាធិរ័ង្ស ហួត-តាត ចាងហ្វាងសាលា, នឹងព្រះតេជព្រះគុណ ព្រះមហាព្រហ្មមុនី ទេព-អ៊ូ ជាចាងហ្វាងរងនៅចាំទទួល ហើយអញ្ជើញលោកទៅមើលក្រុមជំនុំព្រះត្រៃបិដកទៀត ។

នៅម៉ោង ១៨ កន្លះ មហាបណ្ឌិតបានអញ្ជើញទៅជួបនឹងក្រុមអភិបាលនៃសមាគមមិត្តសាលាបាលី នៅឯសាលាបាលីជាន់ខ្ពស់ ដែលមានមហាជនជាងពីរពាន់នាក់បានទៅរួមផង ។ ក្នុងពេលនោះលោក

ក៏យ-ប៊ុក ជាអធិបតីនៃសមាគមមិត្តសាលាបាលី បានថ្លែងបាឋកថាសង្ខេបមួយជាភាសាខ្មែរ ជំរាបមហាបណ្ឌិតឲ្យជ្រាបអំពីពុទ្ធសាសនានៅប្រទេសកម្ពុជរដ្ឋ ដូចតទៅនេះ :–

សូមជំរាបលោកមហាបណ្ឌិតជាអធិបតីពុទ្ធិកសមាគមពិភពលោក !

ខ្ញុំជាតំណាងសមាគមមិត្រសាលាបាលីកម្ពុជរដ្ឋ, សូមអរគុណដ៏ក្រៃលែងចំពោះលោក ដែលបានអញ្ជើញមកទស្សនាប្រទេសកម្ពុជា ៗ ដ្បិតដំណើរមកនៃលោកនេះ ទុកជាមង្គលដ៏ប្រសើរចំពោះព្រះពុទ្ធសាសនា នៅទីនេះ ៗ

មហាបណ្ឌិត ! ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាបានចំរើនរៀងរាបដរាបមក ៗ រដ្ឋបាល បានស្ថាបនាសាលាបាលីជាន់ខ្ពស់មួយ នៅក្រុងភ្នំពេញ និងសាលាបាលីរងចំនួន ២៤៨ ខ្នង និងសាលាធម្មវិន័យជាច្រើន តាមវត្តក្នុងខេត្តស្រុកឃុំ ៗ មានសិស្សប្រឡងចេញអំពីសាលាបាលីរងនោះ ក្នុងមួយឆ្នាំ ៗ ជាង ២០០០ រូប ៗ ឯសាលាបាលីជាន់ខ្ពស់នេះ កើតឡើងពីពុទ្ធសករាជ ២៤៥៧ គិតទៅបាន ៣៧ ឆ្នាំ ៗ សាលាធម្មវិន័យបានកើតឡើងដោយកម្លាំងនៃពុទ្ធមាមកជន ដោយមានព្រះរាជក្រឹត្យអនុញ្ញាតឲ្យបង្កើតនៅក្រោមព្រះបរមរាជូបត្ថម្ភ នៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង ប្រទេសកម្ពុជា ៗ សាលាទាំងនោះ

សុទ្ធតែជាវិជ្ជាស្ថានសំរាប់អប់រំវិជ្ជាខាងព្រះពុទ្ធសាសនា ដើម្បីស្រួយព្រះពុទ្ធសាសនា ឲ្យដើរទៅកាន់សេចក្ដីចំរើនទាន់កាលសម័យ ។

មួយទៀត ពួកពុទ្ធមាមកជននៅក្រុងភ្នំពេញ បានផ្ដើមបង្កើតពុទ្ធិកសមាគម ពីថ្ងៃទី ១៣ ខែតុលា ឆ្នាំ ព.ស. ២៤៨១ មកម្ដងហើយ តែសមាគមនោះតាំងនៅបានត្រឹម ៥ ឆ្នាំហើយក៏ថយកម្លាំងដូចជារលត់ទៅ ។ លុះមកដល់ថ្ងៃទី ២៨ ខែសីហា ឆ្នាំ ព. ស. ២៤៩២ ក៏មានសមាគមមួយទៀត បានចាប់បដិសន្ធិឡើងជាថ្មី មហាសន្និបាតឲ្យនាមថា "សមាគមមិត្រសាលាបាលី" ដែលកើតឡើងដោយកម្លាំងនៃសេចក្ដីព្យាយាមរបស់ពួកពុទ្ធបរិសទ្យបានផ្ដួចផ្ដើមឡើង ។ សមាគមនេះមានវ័យនៅក្មេង ពុំទាន់មានសម្ភារៈគប់គ្រាន់ ពុំទាន់មានទីសំណាក់ការសមសួននៅឡើយ ព្រមទាំងធនធាននៃសមាគមមិត្រសាលាបាលី ក៏នៅស្ដួចស្ដើងណាស់ មិនទាន់មានកំឡាំងមួនមាំ គ្រាន់តែមានដំណើរប្រព្រឹត្តទៅមិនដាច់ប៉ុណ្ណោះ ។ ពីឆ្នាំទៅម៉្យាង គណៈប្រតិភូខែរកម្ពុជរដ្ឋ ទាំងគ្រហស្ថ ទាំងបព្វជិត មានសម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកជាប្រធានបានទៅកាន់មហាពុទ្ធិកសមាគមពិភពលោកនៅលង្កាទ្វីប ។ តាំងពីកាលប្រតិភូខែរត្រឡប់មកពីលង្កាទ្វីបនោះវិញ ពុទ្ធសាសនិកជនខែរមានបំណងបំរុងនឹងរៀបចំទូវពុទ្ធិកសមាគម មជ្ឈមណ្ឌលភូមិភាគ នៅកម្ពុជរដ្ឋមួយទៀត , សំរាប់ប្រស្រ័យផ្សាល់ចំពោះពុទ្ធិកសមាគមពិភពលោក

នៅលង្កាទ្វីប តែមិនទាន់រៀបចំរួចនៅឡើយ ។ ដូចនេះ ខ្ញុំសូមជំរាបលោកមហាបណ្ឌិតថា ពួកពុទ្ធមាមកជននៅទីនេះនឹងខំព្យាយាមចាត់ការបង្កើតសមាគមនេះ ត្រាតែកើតតាមបំណង ។

ក្នុងបរិយោសាននេះ ខ្ញុំសូមធ្វើសច្ចាវាចាថា "ដោយអានុភាពព្រះត្រៃរត្ននឹងអានុភាពវត្ថុសក្តិសិទ្ធិ សូមធម៌បួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ចំរើនដល់លោកនឹងអ្នកលង្កាទ្វីបសព្វកាលកុំបីឃ្លាតឡើយ ! សូមទេវតាដែលរក្សាលង្កាទ្វីប នឹងទេវតាដែលរក្សាកម្ពុជរដ្ឋ ចាប់ដៃគ្នាដោយសាមគ្គីធម៌កសាងព្រះពុទ្ធសាសនាក្នុងសាកលលោក ឲ្យបានប្រកបដោយវឌ្ឍនធម៌តទៅអនាគតហោង" ។

បន្ទាប់មក លោកទិន - ហួត ជាសាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ បានប្រែបាឋកថាភាសាខ្មែរនេះ ទៅជាភាសាបាលីជូនលោកមហាបណ្ឌិតស្តាប់ ដូចយើងនាំមកចុះតទៅនេះ :—

## សុន្ទរកថាបរិវត្តន៍

សកលលោកស្ស មហាពុទ្ធិកសមាគមស្ស អធិបតិ មហាបណ្ឌិត ! អហំ កម្ពុជរដ្ឋ បាលិសិក្ខាគារមិត្តសមាគមស្ស បតិកូ, កម្ពុជរដ្ឋស្ស ទស្សនាយ តុម្ហាកំ អាគមនំ អតិវិយ តុដ្ឋោម្ហិ ។ ឥទំ បន តុម្ហាកំ អាគមនំ ឥធ ពុទ្ធសាសនស្ស សុភមង្គលំ ហោតិ ។

ឥមស្មឹ ទេសេ មហាបណ្ឌិត ពុទ្ធសាសនំ អនុក្កមេន វឌ្ឍតិ ។ កុំពេញ- រាជធានិយំ វឌ្ឍបាលកា ឥស្សរជនា ឧត្តមបាលិសិក្ខាគារំ បតិដ្ឋាបេត្វា គាមនិគមជនបទេសុ វិហារេសុ អដ្ឋបត្តាឡីសុត្តរទ្វិសតានិ អនុបាលិសិក្ខាគារានិ ច ធម្មវិនយសិក្ខាគារានិ ច បតិដ្ឋាបេសុំ ។ សំវច្ឆរេ សំវច្ឆរេ តេហិ អនុបាលិសិក្ខាគារេហិ ទ្វិសហស្សមត្តា សិស្សា អត្តនោ អត្តនោ សិក្ខំ និដ្ឋាបេសុំ ។ តទំ បន ឧត្តមបាលិសិក្ខាគារំ សត្តបញ្ញាសុត្តរបេតុស្សតាធិកទ្វិសហស្សពុទ្ធសកេ ឧប្បន្នំ ។ ឥតោ បដ្ឋាយ យាវជ្ជតនា សត្តតឹស សំវច្ឆរានិ បរិបុណ្ណានិ ។ អបរានិបិ ធម្មវិនយសិក្ខាគារានិ រាជានុញ្ញាតំ និស្សាយ បរមករុបត្តម្ភេ បតិដ្ឋាបិ-តានិ ។ តានិ សិក្ខាគារានិ ពុទ្ធសាសនេ ធម្មវិនយសិក្ខាបនដ្ឋានានិ ច ហោន្តិ ពុទ្ធសាសនស្ស វុឌ្ឍិ វិរុឡ្ហិ សម្បាបនានិ ច ។

អបិ ច កុំពេញ- នគរេ ពុទ្ធមាមកា ឯកាសីត្យុត្តរបេតុស្សតាធិក-ទ្វិសហស្សពុទ្ធសកេ ឯកំ ពុទ្ធិកសមាគមំ បតិដ្ឋាបេសុំ ។ សោបិ-ខោ បញ្ចូ សំវច្ឆរានិ បត្វា បរិហីនសទិសោ អហោសិ ។ អបរេន សមយេន ទ្វេនវុត្យុត្តរបេតុស្សតាធិកទ្វិសហស្សពុទ្ធសកេ ឯកោ ពុទ្ធិក សមាគមោ វឌ្ឍិសិនោ ពុទ្ធមាមកេ និស្សាយ បុន ឧប្បជ្ជតិ ។ ឥមស្ស កម្ពុជភាសាហាវេន "សមាគមមិត្តសាលាបាលី" ឥតិ នាមំ ករីសុ ។ អយញ្ចូ អភិនវោ ពុទ្ធិកសមាគមោ ន តាវ មហប្ផលោ ហោតិ នេវ មហទ្ធនោ ។ អវិច្ចិន្នំ បន សំវត្តតិ ។

អតីតសំវច្ឆរេ មហាសុមេធាធិបតិសង្ឃនាយកត្ថេរប្បមុខា គហដ្ឋប្បព្វជិតា កម្ពុជរដ្ឋពុទ្ធមាមកានំ បតិភូ ហុត្វា លង្កាទីបេ សកលលោកស្ស មហាពុទ្ធិកសមាគមំ គមិំសុ ។ តតោ និវត្តនកាលេ តស្ស មហាពុទ្ធិកសមាគមស្ស បរិពាំ បុល្លពុទ្ធិកសមាគមំ ឥមស្មិំ រដ្ឋេ បតិដ្ឋាបេតុកាមា ហោន្តិ ។ សោ បន ឥទានិ ន តាវ ឧប្បជ្ជតិ ។ ឥធ បន មហាបណ្ឌិត ពុទ្ធមាមកា តំ អវិជ្ជហិត្វា បតិដ្ឋាបេតុំ វាយមន្តិ ។ សោ សមាគមោ ឧប្បជ្ជិស្សតិ យេវ ។

កថាបរិយោសានេ រតនត្តយស្សានុភាវេន ចេវ សកលលោកេ មហិទ្ធិកវត្ថុម្ហិ អានុភាវេន ច "អាយុ វណ្ណោ សុខំ ពលំ" ឥតិ ចត្តារោ ធម្មា តុម្ហាកញ្ច លង្កាទីបវាសិនញ្ច វឌ្ឍន្តូ'តិ សព្វេបនំ កពេមិ ។

លង្កាទីបារក្ខកា ច កម្ពុជរដ្ឋារក្ខកា ទេវតា ច មេត្តចិត្តេន អញ្ញមញ្ញស្ស ហិតេ គហេត្វា សមគ្គា ហុត្វា ពុទ្ធសាសនំ វុឌ្ឍាបេន្តុ ។

(មា.ឧត)